# អង្គការដៃគូដើម្បីការអភិវឌ្ឍជនបទ
# (ភី អ ឌី)

# របាយការណ៍ប្រចាំឆ្នាំ មករា-ធ្នូ ២០២៣
# គម្រោងការអប់រំដើម្បីការអភិវឌ្ឍន៍





**កាលបរិច្ឆេទ៖ ថ្ងៃចន្ទ ទី១២ ខែកុម្ភៈ ឆ្នាំ ២០២៣**
**រៀបចំដោយ៖ លោក បឿត ចាន់តុលា**

# អង្គការដៃគូដើម្បីការអភិវឌ្ឍជនបទ ( ភី អរ ឌី )

*****

# របាយការណ៍ប្រចាំឆ្នាំ ២០២៣

## គម្រោងអនុវត្តពី ខែមករា ដល់ខែធ្នូ ឆ្នាំ២០២៣

# គម្រោងអប់រំដើម្បីការអភិវឌ្ឍ

(គម្រោងផ្តោតលើស្រ្តី និងក្មេងស្រី)

**មាតិកា** **ទំព័រ**


សារលិខិតរបស់ភី អ ឌី .......... ១
បេសកម្ម .......... ១
និរន្តភាព .......... ១-២
តំបន់គោលដៅ .......... ២
កម្មវិធីធំៗរបស់ភី អ ឌី .......... ៣
លទ្ធផលសម្រេចបានពីការអនុវត្តកម្មវិធីឆ្នាំ២០២៣ .......... ៣
១. គម្រោងសមភាព សមធម៌ យេនឌ័រ .......... ៣-៤
២. គម្រោងការអប់រំដើម្បីការអភិវឌ្ឍសម្រាប់ឆ្នាំ២០២៣ .......... ៤
២.១. គម្រោងពង្រឹងសមត្ថភាពកម្រិតមត្តេយ្យ និងបឋមសិក្សា .......... ៤-១២
២.២. សកម្មភាពក្លឹបសិក្សានៅបឋមសិក្សា .......... ១២
២.២.១ ក្លឹបភាសាអង់គ្លេសសម្រាប់ក្មេងស្រី .......... ១៣
២.២.២ ក្លឹបកីឡាសម្រាប់ក្មេងស្រី .......... ១៤-១៦
២.២.៣ ក្លឹបបរិស្ថានសម្រាប់ក្មេងស្រី .......... ១៧-១៩
២.២.៤ សកម្មភាពបណ្ណាល័យ និងក្លឹបអានសម្រាប់ក្មេងស្រី .......... ១៩-២២
២.២.៥ សកម្មភាពបំណិនជីវិត និងសួនបន្លែសាលារៀន .......... ២២-២៣
២.៣. គម្រោងនៅវិទ្យាល័យ .......... ២៣
២.៣.១ ក្លឹបកុំព្យូទ័រសម្រាប់ក្មេងស្រី .......... ២៣-២៤
២.៣.២ សកម្មភាពSTEM សម្រាប់ក្មេងស្រី .......... ២៤
២.៣.៣ គម្រោងក្លឹបភាសាអង់គ្លេសសម្រាប់ក្មេងស្រី .......... ២៥
២.៤. គម្រោងអាហារូបករណ៍សម្រាបស់សិស្សស្រី .......... ២៥-២៨
៣. គម្រោងអភិរក្សវប្បធម៌ និងភាសារបស់ជនជាតិដើមភាគតិច (ព័រ) .......... ២៨
៣.១. គម្រោងក្លឹបភាសាជនជាតិព័រ .......... ២៨-២៩
៣.២ គម្រោងអភិរក្សវប្បធម៌ជនជាតិព័រ .......... ២៩-៣០
៤. កិច្ចសហប្រត្តិបត្តការនានា និងដៃគូ .......... ៣០-៣១
៥. របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៣ .......... ៣២-៣៤


- **បញ្ជីឧបសម្ព័ន្ធបន្ថែម**


បញ្ជីអក្សរកាត់ .......... ៣៥
កិច្ចសហប្រតិបត្តិការភាពជាដៃគូក្នុងស្រុក .......... ៣៥
ប្រភពម្ចាស់ជំនួយ .......... ៣៦

**សាវតារបស់ភី អ ឌី**

អង្គការដៃគូដើម្បីការអភិវឌ្ឍជនបទ(ភីអឌី)គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនៃប្រទេសកម្ពុជាដែលមានស្ត្រីជាអ្នកដឹកនាំហើយបានទទួលលិខិតប្រកាសទទួលស្គាល់ការចុះបញ្ជីរអង្គការពីក្រសួងមហាផ្ទៃនៅក្នុងខែមករាឆ្នាំ២០១៧ ជាអង្គការមិនរកប្រាក់ចំណេញ មិនបំរើគណៈបក្សនយោបាយ និងមិនរើសអើងចំពោះមនុស្សគ្រប់រូបជាពិសេសនៅក្នុងសហគមន៍គោលដៅ។

អង្គការ ភីអឌី ធ្វើការនៅតំបន់ដាច់ស្រយាលនិងក្រីក្របំផុតនៅខេត្តបាត់ដំបងស្រុកសំឡូតនិងខេត្តប៉ៃលិននិងមានការិយាល័យកណ្ដាលនៅទីរួមខេត្តបាត់ដំបង។ ការិយាល័យកណ្ដាលជាអ្នកផ្ដល់សេវាគាំទ្រទូទៅលើគ្រប់ផ្នែកទាំងអស់និងជាអ្នករក្សាទំនាក់ទំនងជិតស្និទ្ធិជាមួយអ្នកអនុវត្តគម្រោងព្រមទាំងដៃគូពិគ្រោះយោបល់ទាំង
អស់។

អង្គការ ភីអឌី បានបង្កើតទំនាក់ទំនងល្អជាមួយដៃគូទាំងអស់ដែលពាក់ព័ន្ធក្នុងកម្មវិធីអប់រំ។ អង្គការ ភីអឌីមានគោលបំណងជាក់លាក់លើការកំណត់ពីភាពជោគជ័យភាពរីកចម្រើននិងការអនុវត្តកម្មវិធីនៅក្នុងតំបន់ដោយធ្វើការសហការល្អជាមួយនាយកសាលា លោកគ្រូអ្នកគ្រូ ការិយាល័យអប់រំស្រុក និងអាជ្ញាធរមូលដ្ឋាន។

<u>**បេសកកម្ម៖**</u> បេសកកម្មរបស់យើងគឺដើម្បីផ្ដល់អោយកុមារីនិងស្ត្រីនៅតាមជនបទនៅភាគពាយព្យនៃប្រទេសកម្ពុជា អោយមានជំនាញនិងការគាំទ្រដែលចាំបាច់ដើម្បីកសាងសហគមន៍ដែលមានសុខភាពល្អ ដោយសន្តិភាព និងការបង្រួបបង្រួមសហគមន៍។ ទោះបីជាការផ្ដោតអារម្មណ៍របស់យើងជាមួយនឹងក្មេងស្រីនិងស្ត្រី ក៏គម្រោងរបស់យើងនឹងផ្សារភ្ជាប់ទៅក្មេងប្រុសនិងបុរសដែរ។

<u>**និរន្តភាព៖**</u> ផែនការណ៍យុទ្ធសាស្ត្ររបស់អង្គការ ភីអឌី សម្រាប់ឆ្នាំ ២០២០~២០២៣ បន្តរការងារដែលបានអនុវត្តចាប់ពីឆ្នាំ ២០១៧ រហូតដល់ឆ្នាំ ២០២២និងអនុវត្តដោយផ្អែកតាមយុទ្ធសាស្ត្រចតុកោណរបស់រាជ្យរដ្ឋាភិបាលកម្ពុជាជំហានទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩~២០២៣ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិដែលផ្ដោតលើគោលដៅយុទ្ធសាស្ត្រ ទី៤,៥,៦និងទី១៣ ដែលមានចែងដូចខាងក្រោម៖

**គោលដៅទី៤៖ ការអប់រំប្រកបដោយគុណភាព៖** ធានាឱ្យមានការអប់រំប្រកបដោយគុណភាព និងរួមបញ្ចូលសម្រាប់ទាំងអស់គ្នា និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។

**គោលដៅទី៥៖ សមភាពយេនឌ័រ៖** សម្រេចបានសមភាពយេនឌ័រ និងផ្ដល់សិទ្ធិអំណាចដល់ស្ត្រី និងកុមារីទាំងអស់។

**៥.៥៖** ធានាឱ្យមានការចូលរួមយ៉ាងពេញលេញ និងមានប្រសិទ្ធភាពរបស់ស្ត្រី និងឱកាសស្មើគ្នាសម្រាប់ការដឹកនាំនៅគ្រប់កម្រិតនៃការសម្រេចចិត្តក្នុងជីវិតនយោបាយ សេដ្ឋកិច្ច និងសាធារណៈ។

**គោលដៅទី៦៖ អនាម័យ ទឹកស្អាត និងអនាម័យទូទៅ៖** ធានាឱ្យមានលទ្ធភាព និងការគ្រប់គ្រង ប្រកបដោយនិរន្តរភាពនៃទឹក និងអនាម័យសម្រាប់ទាំងអស់គ្នា។

**គោលដៅទី១៣៖ សកម្មភាពអាកាសធាតុ៖** ចាត់វិធានការបន្ទាន់ ដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់របស់វា។

អង្គការ ភីអឌី យល់ពីសារៈសំខាន់នៃការធ្វើការសហប្រតិបត្តិការជាមួយដៃគូពាក់ពន្ធ័ដើម្បីអោយមានការអភិវឌ្ឍន៍ដោយមាននិរន្តភាព។ ភី អ ឌី ធ្វើការជាមួយសហគមន៍ទាំងមូលដោយមិនរើសអើងក៏ដូចជាធ្វើការជាមួយសាលាដែលមានសិស្សានុសិស្ស ឪពុកម្តាយ លោកគ្រូអ្នកគ្រូ លោកនាយក អ្នកដឹកនាំសហគមន៍ អាជ្ញាធរដែនដីគ្រប់កំរិត ការិយាល័យអប់រំស្រុក ការិយាល័យកិច្ចការនារីស្រុក និងមន្ទីរពាក់ពន្ធ័នៅក្នុងខេត្ត ដៃគូរអង្គការជាតិនិងអន្តរជាតិ។

## <u>តំបន់គោលដៅ</u>

អង្គការ ភី អ ឌី បានអនុវត្តគម្រោងនៅតាមតំបន់ដាច់ស្រយាលក្នុងស្រុកសំឡូត ខេត្តបាត់ដំបង និងស្រុកសាលាក្រៅ និងក្រុងទេពនិម្មិត ខេត្តប៉ៃលិនដែលមាន១៨ភូមិគោលដៅ ភូមិគោលដៅ១០ស្ថិតនៅក្នុងបរិវេណសាលាគោលដៅទាំង១០របស់អង្គការដែលមានសាលា៧ស្ថិតនៅក្នុងខេត្តបាត់ដំបង ស្រុកសំឡូតនិងសាលា៣ស្ថិតនៅក្នុងខេត្តប៉ៃលិន។ ក្នុងសាលាគោលដៅទាំង៨ អង្គកាភីអឌី ផ្តោតទៅលើ២កំរិតសិក្សាគឺកំរិតមត្តេយ្យនិងកំរិតបឋមសិក្សាចាប់ពីថ្នាក់ទី១ដល់ទី៦ ដែលមានសិស្សសរុបប្រហែល ១៥៤៥នាក់ ក្នុងនោះសិស្សកំរិតមត្តេយ្យមានចំនួន២៤៣ នាក់ (ក្មេងស្រី១២០នាក់) និងសិស្សបឋមសិក្សា ១៣០២នាក់ក្នុងនោះស្រី៦២៤នាក់។

នៅឆ្នាំ ២០២៣ ភី អ ឌី បានពង្រីកទៅតំបន់គោលដៅថ្មីក្នុងឃុំតាតោកដែលធ្វើការនៅសាលាបឋមសិក្សាភ្នំរ៉ៃ និងសាលាបឋមសិក្សាសុខសាន្ត រួមទាំងធ្វើការជាមួយជនជាតិដើមភាគតិចព័រផងដែរ។ នៅតំបន់គោលដៅថ្មីនេះ មានសិស្សចំនួន ២៣០នាក់ (ស្រី ១០៨នាក់ និងសិស្សជនជាតិដើមភាគតិចព័រ ៩៣នាក់) សិក្សានៅសាលាបឋមសិក្សាភ្នំរ៉ៃ និងសាលាបឋមសិក្សាសុខសាន្ត និងសិស្សថ្នាក់មត្តេយ្យ ៤៧នាក់ (ស្រី ៣០នាក់ និងសិស្សជនជាតិដើមភាគតិចព័រ ១៥នាក់) នៅសាលាមត្តេយ្យភ្នំរ៉ៃ សាលាមត្តេយ្យសហគមន៍សុខសាន្ត និងមត្តេយ្យសហគមន៍នៅក្រុមទី១២។

អង្គការបានជ្រើសរើសសាលាគោលដៅទាំង ១០នេះ ដោយសារតែសាលាទាំង១០ស្ថិតនៅក្នុងតំបន់ដាច់ស្រយ៉ាល ដូច្នេះអង្គការ ភី អ ឌី បានចូលរួមចំណែកអនុវត្តគម្រោងការអប់រំដើម្បីការអភិវឌ្ឍនៅតាមតំបនសាលាគោលដៅទាំងនោះ ក្នុងគោលបំណងរួមចំណែកជាមួយរាជ្យរដ្ឋាភិបាលដើម្បីជួយដល់កុមារក្រីក្រនៅជនបទ។

***សូមពិនិត្យតារាងឈ្មោះសាលាគោលដៅនដែលបានភ្ជាបនៅក្នុងបញ្ជីឧបសម្ព័ន្ធ***

## កម្មវិធីធំៗរបស់អង្គការ

កម្មវិធីរបស់អង្គការ(ភីអឌី)ផ្តោតលើសកម្មភាពធំៗដូចខាងក្រោម៖

- ការអប់រំបរិស្ថាន
- សមភាពយេនឌ័រ(ការចុះអប់រំផ្សព្វផ្សាយ)
- អប់រំសុខភាពបឋម និង អនាម័យ
- កម្មវិធីអប់រំចំណេះទូទៅ
- កសិកម្ម

## ១. កម្មវិធីដែលសម្រេចបានសម្រាប់ឆ្នាំ២០២៣

### ១.១. គម្រោង សមភាពយេនឌ័រ និង សមធម៌យេនឌ័រ

ការទទួលបានសមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចរបស់ស្ត្រីពេញលេញនៅពេលដែលស្ត្រី និងបុរសទទួលបានសិទ្ធិ និងឱកាសដូចគ្នានៅគ្រប់ផ្នែកទាំងអស់នៃសង្គម រួមទាំងការចូលរួមផ្នែកសេដ្ឋកិច្ច និងការសម្រេចចិត្ត ហើយនៅពេលដែលការប្រព្រឹត្ត សេចក្តីប៉ងប្រាថ្នា និងតម្រូវការខុសៗគ្នារបស់ស្ត្រី និងបុរសត្រូវបានផ្តល់តម្លៃ និងពេញចិត្តស្មើៗគ្នា។

អំពើហឹង្សាផ្អែកលើយេនឌ័រដែលទាក់ទងនឹងសាលារៀន (SRGBV) គឺជាឧបសគ្គយ៉ាងធ្ងន់ធ្ងរក្នុងការសម្រេចបានសមភាពយេនឌ័រ។ ការអប់រំមានសារៈសំខាន់ក្នុងការពង្រឹង និងផ្លាស់ប្តូរជីវិតរបស់យុវជន ជាពិសេសកុមារី ប៉ុន្តែ SRGBV រីករាលដាលធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការសម្រេចបាននូវការអប់រំប្រកបដោយគុណភាព រួមបញ្ចូល និងសមធម៌សម្រាប់ក្មេងស្រី និងក្មេងប្រុស។

សាលារៀន ផ្ទះ និងសហគមន៍គឺជាបរិយាកាសដែលល្អសម្រាប់ការកសាងអត្តសញ្ញាណយេនឌ័រ ហើយទំនាក់ទំនងយេនឌ័រ។ អង្គការ ភីអឌី កំពុងធ្វើការដើម្បីធានាថាអត្តសញ្ញាណយេនឌ័រ និងទំនាក់ទំនងទាំងនេះត្រូវបានបង្កើតឡើងនៅលើគោលការណ៍សមភាពយេនឌ័រ។ អង្គការ ភីអឌី បានអនុវត្តគោលការណ៍ សមភាពនិងសមធម៌យេនឌ័រផ្ទាល់នៅក្នុងគ្រប់កម្មវិធីរបស់ខ្លួន។

នៅឆ្នាំ ២០២៣ ភី អ ឌី បានធ្វើការជាមួយ គ.ក.ន.ក នាយកសាលា និងគណៈកម្មាធិការគ្រប់គ្រងសាលារៀននៅឃុំតាសាញ់ ឃុំអូរសំរិល និងសង្កាត់មានជ័យ ដើម្បីពិភាក្សា និងរៀបចំផែនការធ្វើសិក្ខាសាលាជាមួយឪពុកម្តាយ។ នៅថ្ងៃទី ១២ និងទី១៧ ខែតុលា ឆ្នាំ ២០២៣ ភី អ ឌី បានធ្វើសិក្ខាសាលា

ជាមួយឪពុកម្តាយចំនួន ១១៥ នាក់ (ស្រី ៧៩ នាក់) នៅសាលាបឋមសិក្សាដូនត្រឹត មានជ័យ និង ទ្រុងខ្លា លើប្រធានបទមួយចំនួនដូចខាងក្រោមៈ

- តួនាទី និងទំនួលខុសត្រូវរបស់ស្ត្រីក្នុងការសម្រេចចិត្តក្នុងគ្រួសារ ឬសហគមន៍។
- អំពើហិង្សាក្នុងគ្រួសារបណ្តាលឲ្យកុមារបោះបង់ការសិក្សា
- ការចិញ្ចឹមកូនបែបវិជ្ជមាន
- ការអប់រំរបស់ឪពុកម្តាយនិងកូន
- សារៈសំខាន់របស់ឪពុកម្តាយ និងការចូលរួមរបស់សាលា

## ២. គម្រោងពង្រឹងសមត្ថភាពកម្រិតមត្តេយ្យ និងបឋមសិក្សា

### ២.១. កម្មវិធីសាលាមត្តេយ្យសិក្សា

#### ២.១.១ សាលាមត្តេយ្យសហគមន៍

បច្ចុប្បន្ននេះ សាលាមត្តេយ្យសហគមន៍នៅតែត្រូវបានគ្រប់គ្រង និងគាំទ្រដោយគណៈ កម្មាធិការឃុំ ប៉ុន្តែសាលាមត្តេយ្យសហគមន៍បានផ្លាស់ប្តូរពីផ្ទះរបស់អ្នកភូមិមកសិក្សានៅសាលារដ្ឋ និងសាលាឧបសម្ព័ន្ធនៅជិតភូមិរបស់គេ។ គ្រូមត្តេយ្យសិក្សា (ជាប់កិច្ចសន្យាប្រចាំឆ្នាំ និងគ្មានជំនាញគរុកោសល្យ) នៅតែទទួលបានជំនួយប្រចាំខែពីមូលនិធិឃុំ។ ទោះជាយ៉ាងនេះក្តី គណៈកម្មាធិការឃុំបានសហការជាមួយនាយកសាលារដ្ឋ និងការិយាល័យអប់រំស្រុក ដើម្បីបណ្តុះបណ្តាលគ្រូទាំងនោះ ឱ្យក្លាយជាគ្រូស្តង់ដារ ដែលមានជំនាញគរុកោសល្យពេញលេញ ដើម្បីឱ្យពួកគេអាចទទួលបានប្រាក់បៀវត្សរ៍ប្រចាំខែពីក្រសួងអប់រំ យុវជន និងកីឡា ៥០ ភាគរយពីមូលនិធិឃុំពីមុន។ ខាងក្រោមជាស្ថិតិសិស្សមត្តេយ្យសហគមន៍ៈ

| ល.រ | ឈ្មោះសាលាមត្តេយ្យ | សិស្សសរុប | ស្រី | ប្រុស | ផ្សេងៗ |
|---|---|---|---|---|---|
| ក | គោលដៅស្រុកសំឡូត | | | | |
| ១ | សាលាមត្តេយ្យសហគមន៍វាលធ្នា | 15 | 8 | 7 | |
| ២ | សាលាមត្តេយ្យសហគមន៍បុស្សរការ | 19 | 1 | 18 | |
| ៣ | សាលាមត្តេយ្យសហគមន៍អូរអន្សង | 16 | 9 | 7 | |
| ៤ | សាលាមត្តេយ្យសហគមន៍ទ្រុងខ្លា | 15 | 9 | 6 | |
| ៥ | សាលាមត្តេយ្យសហគមន៍ក្រុម១២ | 15 | 9 | 6 | |
| ៦ | សាលាមត្តេយ្យសហគមន៍សុខសាន្ត | 12 | 9 | 3 | |
| | Total | 92 | 45 | 47 | |

## ២.១.២ កម្មវិធីសាលាមត្តេយ្យសិក្សារដ្ឋ

អង្គការភី អ ឌី ក៏បានធ្វើការជាមួយមត្តេយ្យសិក្សារដ្ឋចំនួន ៨ថ្នាក់ ហើយថ្នាក់មត្តេយ្យទាំងនោះត្រូវបានរាយក្នុងតារាងខាងក្រោម៖

| | | | | | |
|---|---|---|---|---|---|
| **ខ** | **មត្តេយ្យសិក្សារដ្ឋនៅស្រុកសំឡូត** | | | | |
| ១ | សាលាបឋមសិក្សាមានជ័យ | 45 | 24 | 21 | |
| ២ | សាលាឧបសម្ព័ន្ធមានជ័យ | 15 | 8 | 15 | |
| ៣ | សាលាបឋមសិក្សាដូនត្រីត | 22 | 10 | 12 | |
| ៤ | សាលាឧបសម្ព័ន្ធដូនត្រីត | 14 | 7 | 7 | |
| ៥ | សាលាបឋមសិក្សាព្រៃរំចក | 26 | 13 | 13 | |
| ៦ | សាលាបឋមសិក្សាភ្នំរ៉ៃ | 20 | 12 | 8 | 15 ជនជាតិព័រ |
| **គ** | **មត្តេយ្យសិក្សារដ្ឋនៅក្រុងទេពនិម្មិត្ត ខេត្តប៉ៃលិន** | | | | |
| ១ | សាលាបឋមសិក្សាទឹកផុស | 23 | 8 | 15 | |
| ២ | សាលាបឋមសិក្សាពេជ្រគីរី | 20 | 10 | 10 | |
| | **ចំនួនសិស្សមត្តេយ្យរដ្ឋសរុប** | **165** | **80** | **93** | |

## ២.១.៣ កម្មវិធីពង្រឹងសមត្ថភាពមត្តេយ្យសិក្សារដ្ឋ និងមត្តេយ្យសិក្សាសហគមន៍

អង្គការដៃគូដើម្បីការអភិវឌ្ឍជនបទ (PRD) បានសហការជាមួយការិយាល័យអប់រំស្រុកសំឡូត និងក្រុងប៉ៃលិន បានរៀបចំវគ្គបណ្តុះបណ្តាលពីវិធីសាស្ត្របង្រៀនដល់លោកគ្រូអ្នកគ្រូនៅតាមសាលាគោលដៅ។ កាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២៣ ការិយាល័យអប់រំ យុវជន និងកីឡាស្រុកសំឡូត បានរៀបចំសិក្ខាសាលា ស្តីពីការរំលឹកឡើងវិញពីវិធីសាស្ត្របង្រៀននៅកម្រិតមត្តេយ្យសិក្សាទាំងរដ្ឋ និងមត្តេយ្យសហគមន៍នៅសាលាស្រុកសំឡូត ដល់លោកគ្រូអ្នកគ្រូចំនួន ១៨នាក់ (ស្រី ១៦នាក់) ក្រោមប្រធានបទដូចខាងក្រោម៖

- បច្ចេកទេសបង្រៀន និងវិធីសាស្ត្របង្រៀន
- ហ្គេមសប្បាយជាមួយនឹងការរៀនកំពុងលេង។
- ចម្រៀង និងសិល្បៈ មុនបង្រៀនភាសាខ្មែរ និងសិក្សាមុនគណិតវិទ្យា។
- ការតុបតែងថ្នាក់រៀន និងផលិតសម្ភារៈសម្រាប់បង្រៀន និងរៀន។

នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ ភី អ ឌី បានសហការជាមួយប្រធានការិយាល័យអប់រំក្រុងប៉ៃលិន ផ្ដល់ការបណ្ដុះបណ្ដាលបច្ចេកទេស និងវិធីសាស្ត្របង្រៀនដល់លោកគ្រូ អ្នកគ្រូថ្នាក់មត្តេយ្យចំនួន ៤នាក់ (ស្រី៤នាក់) មកពីសាលាបឋមសិក្សាចំនួន២ គឺសាលាបឋមសិក្សាពេជ្រគិរី និងទឹកផុស និងជំនួយការសាលាក្រុងប៉ៃលិនចំនួន៣នាក់ ក្រោមប្រធានបទដូចខាងជា៖ - បង្រៀនភ្លេង - ផលិតសម្ភារៈ និងតុបតែងថ្នាក់ - បង្រៀនបុរេភាសាខ្មែរ - ការបង្រៀនបុរេគណិតវិទ្យា ចិត្តចលភាព - គំនូរជីវចល ។ល។

ភី អ ឌី ក៏បានផ្ដល់សិក្ខាសាលាអភិវឌ្ឍន៍វិជ្ជាជីវៈចំនួន ៤វគ្គបន្ថែម សម្រាប់គ្រូបង្រៀន នៅតំបន់គោលដៅភ្នំរ៉ៃ និងសុខសាន្ត ដើម្បីពង្រឹងជំនាញបង្រៀនរបស់ពួកគេ និងផលិតសម្ភារៈបង្រៀនដល់គ្រូបង្រៀន មត្តេយ្យចំនួន ២ នាក់ និងសាលាមត្តេយ្យសហគមន៍ចំនួន ១ និងសហការជាមួយអ្នកជំនាញមត្តេយ្យក្នុងស្រុកសំឡូត ធ្វើការត្រួតពិនិត្យថ្នាក់រៀននៅក្នុងសហគមន៍ មត្តេយ្យសិក្សាចរិយា និងភ្នំរ៉ៃ។ សិក្ខាសាលាផ្ដោតលើប្រធានបទដូចជា៖ វិធីសាស្ត្របង្រៀនបុរេភាសាខ្មែរ និងបុរេគណិតវិទ្យា ផលិតសម្ភារៈបង្រៀន និងចែករំលែកពីរបៀបប្រើប្រាស់ឯកសារបង្រៀន







## ២.១.៤ ការគាំទ្រសម្ភារៈបង្រៀន និងរៀនដល់សាលាគោលដៅ

អង្គការដៃគូដើម្បីការអភិវឌ្ឍនជនបទ (ភី អ ឌី) បានផ្ដល់សម្ភារៈបង្រៀន និងរៀន១ដងដល់សាលាគោលដៅចំនួន១០សាលានៅសំឡូត និងប៉ៃលិន រួមទាំងសាលាឧបសម្ព័ន្ធចំនួន ៤នៅស្រុកសំឡូត ដើម្បីគាំទ្រការផលិតសម្ភារៈសិក្សា ការតុបតែងថ្នាក់រៀន និងការណែនាំសម្រាប់ថ្នាក់មត្តេយ្យសហគមន៍ និងរដ្ឋ។ សាលានីមួយៗបានទទួល៖ សៀវភៅពណ៌ សៀវភៅកិច្ចការផ្ទះ ក្រដាសកាតុងធ្វើកេស ក្រដាសបិទផ្សាយ ក្រដាសពណ៌ ក្រមួន ប៊ិចសរសេរ ពណ៌ទៀន រូបចតកម្រាលឈើ ក្រដាស/កាសែតប្លាស្ទិក បន្ទាត់វែង ផ្ទាំងរូបភាព។ ភី អ ឌី ក៏បានផ្ដល់សៀវភៅមួយចំនួនសម្រាប់មុខវិជ្ជាវិទ្យាសាស្ត្រ ដូចជា សៀវភៅសិក្សា គំនូរជីវចល លេខ និងសៀវភៅពណ៌ ដល់ថ្នាក់មត្តេយ្យចំនួន ១១ ថ្នាក់ ប៉ៃលិនចំនួន ២ ថ្នាក់ និងនៅសំឡូតចំនួន ៩ ថ្នាក់ សរុបសៀវភៅចំនួន ៩៩០ ក្បាល។ ភី អ ឌី ក៏បានផ្ដល់សម្ភារៈក្មេងលេង និងសម្ភារៈបង្រៀន និងរៀនដល់គ្រូបង្រៀន និងកុមារមត្តេយ្យសិក្សា (ផ្ដល់ជូន 2 ដងក្នុងមួយឆ្នាំ) នៅភ្នំរ៉ៃ និងសុខសាន្ត។





### ២.១.៥ ការចុះពិនិត្យ និងវាយតម្លៃការបង្រៀនតាមសាលាគោលដៅ

ភី អ ឌី បានសហការជាមួយការិយាល័យអប់រំសំឡូត និងប៉ៃលិន និងអ្នកទទួលបន្ទុកការិយាល័យមត្តេយ្យដើម្បីធ្វើផែនការចុះអង្កេតថ្នាក់រៀន និងវាយតម្លៃសមត្ថភាពបង្រៀនរបស់គ្រូនៅថ្ងៃទី ២៥ ខែកញ្ញា ២៦ ថ្ងៃទី ២៧ និងថ្ងៃទី ០៣ ទី ០៤ ទី ០៥ ខែតុលា ឆ្នាំ២០២៣។ ភី អ ឌី និង អ្នកទទួលបន្ទុកការិយាល័យមត្តេយ្យចុះអង្កេតថ្នាក់រៀន និងវាយតម្លៃបាន ៦ថ្នាក់ (៤ថ្នាក់នៅសំឡូត និង២ថ្នាក់នៅប៉ៃលិន)។ បន្ទាប់ពីធ្វើការសង្កេតក្នុងថ្នាក់រៀន អ្នកទទួលបន្ទុកការិយាល័យមត្តេយ្យ ទាំងសំឡូត និងប៉ៃលិន បានចែករំលែកលទ្ធផលសង្កេត រួមមាន មតិកែលម្អ និងអនុសាសន៍ជាមួយ ភី អ ឌី និង គ្រូមត្តេយ្យសិក្សា។ ការសង្កេតផ្តោតលើព័ត៌មានសំខាន់ៗដូចជា៖ (១) ការគ្រប់គ្រងថ្នាក់រៀន រួមមាន តារាងរដ្ឋបាល សៀវភៅគ្រូ ការតុបតែងថ្នាក់រៀន សម្ភារៈជ្រុងក្នុងថ្នាក់ និងអនាម័យ (២) ជំនាញបច្ចេកទេសក្នុងការបង្រៀន (៣) ការអនុវត្តការបង្រៀន និងរៀន (៤) ការវាយតម្លៃ (៥) មតិកែលម្អរបស់អ្នកសង្កេតការណ៍ និង (៦) ជំហានសកម្មភាពរបស់គ្រូមត្តេយ្យ។





### ២.១.៦ កម្មវិធីប្រជុំអាណាព្យាបាលជាមួយមត្តេយ្យសិក្សា

ភី អ ឌី បានសហការជាមួយនាយកសាលា គណៈកម្មាធិការសាលា និងក្រុមប្រឹក្សាឃុំទទួលបន្ទុកស្ត្រី និងកុមារ (CCWC) ដើម្បីដឹកនាំរៀបចំការប្រជុំផ្តោតលើការជួបជាមួយឪពុកម្តាយសិស្សនៅក្នុងសាលារៀនគោលដៅរបស់ ភី អ ឌី ។ កិច្ចប្រជុំនេះធ្វើឡើងនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២៣ ចាប់ពីម៉ោង ៨ព្រឹក ដល់ម៉ោង ១១ព្រឹក និងម៉ោង ១:៣០ ដល់ម៉ោង ៤:៣០រសៀល ដោយមានអ្នកចូលរួម

ចំនួន ៥១នាក់ (ស្រី ៤២នាក់) នៅសាលាបឋមសិក្សាទ្រុងខ្លា និងសាលាបឋមសិក្សាមានជ័យ ដែលរួមមានមាតាបិតា គណៈកម្មាធិការសាលា និងលោកគ្រូ អ្នកគ្រូផងដែរ។ កិច្ចប្រជុំនេះបានផ្ដោតអំពីៈ

- ការចូលរួមរបស់សាលា និងសហគមន៍
- ចិញ្ចឹមកូនបែបវិជ្ជមាន និងការចូលរួមរបស់កុមារ
- ការអភិវឌ្ឍន៍កុមារ និងទំនាក់ទំនងសង្គម
- សិទ្ធិកុមារ និងអនាគតរបស់កុមារ
- តួនាទី និងទំនួលខុសត្រូវរបស់ឪពុកម្ដាយ




### ២.១.៧ កម្មវិធីសាលាបឋមសិក្សា

នៅឆ្នាំ២០២៣ អង្គការ ភី អ ឌី បានបន្តធ្វើការជាមួយសាលាបឋមសិក្សាចំនួន ១៤ សាលា ដែលមានសាលាចំនួន១១ ស្ថិតក្នុងស្រុកសំឡូត ហើយក្នុងចំណោម១១សាលានោះ មានសាលាឧបសម្ព័ន្ធចំនួន៤ផងដែរ និងមានសាលាចំនួន៣ ទៀតស្ថិតក្នុងខេត្តប៉ៃលិន។

| ឈ្មោះសាលាគោលដៅ | សិស្សសរុប | ស្រី | ផ្សេងៗ |
|---|---|---|---|
| ស្រុកសំឡូត | | | |
| សាលាបឋមសិក្សាមានជ័យ | 171 | 78 | |
| សាលាឧបសម្ព័ន្ធមានជ័យ | 86 | 44 | |
| សាលាបឋមសិក្សាវាលធ្នា | 89 | 38 | |
| សាលាឧបសម្ព័ន្ធវាលធ្នា | 59 | 24 | |
| សាលាបឋមសិក្សាទ្រុងខ្លា | 95 | 48 | |
| សាលាឧបសម្ព័ន្ធទ្រុងខ្លា | 36 | 11 | |
| សាលាបឋមសិក្សាដូនត្រីត | 100 | 57 | |
| សាលាឧបសម្ព័ន្ធដូនត្រីត | 42 | 24 | |
| សាលាបឋមសិក្សាព្រៃរំចេក | 168 | 71 | |
| សាលាបឋមសិក្សាភ្នំរ៉ៃ | 150 | 74 | ជនជាតិព័រ៩០ |
| សាលាបឋមសិក្សាសុខសាន្ត | 80 | 34 | ជនជាតិព័រ៣ |

| | | | |
|---|---|---|---|
| **ចំនួនសិស្សសរុបនៅស្រុកសំឡូត** | 1076 | 503 | |
| សាលាគោលដៅខេត្តប៉ៃលិន | | | |
| សាលាបឋមសិក្សាពេជ្រគីរី | 163 | 87 | |
| សាលាបឋមសិក្សាទឹកផុស | 155 | 73 | |
| សាលាបឋមសិក្សាអណ្តូងថ្ម | 138 | 69 | |
| **ចំនួនសិស្សសរុបនៅប៉ៃលិន** | 456 | 229 | |
| **ចំនួនសិស្សសរុបនៅស្រុកសំឡូត និងប៉ៃលិន** | 1532 | 732 | |

### ២.១.៨ ការពង្រឹងសមត្ថភាពបង្រៀននៅកម្រិតបឋមសិក្សា

អង្គការ ភី អ ឌី បានធ្វើការប្រជុំជាមួយការិយាល័យអប់រំស្រុកសំឡូត និងការិយាល័យអប់រំក្រុងប៉ៃលិនដើម្បីពិភាក្សាពីតម្រូវការចាំបាច់របស់លោកគ្រូអ្នកគ្រូនៅតាមសាលាគោលដៅរបស់អង្គការ ក្នុងគោលបំណងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព បច្ចេកទេស និងវិធីសាស្រ្តថ្មីក្នុងការបង្រៀននិងរៀន។

នៅខែមករា ឆ្នាំ 2023 ភី អ ឌី បានបើកសិក្ខាសាលាពង្រឹងសមត្ថភាពគ្រូនៅសាលាបឋមសិក្សាភ្នំរ៉ៃ និងសុខសាន្ត។ គ្រូបង្រៀនចំនួន ១៤នាក់ ក្នុងនោះមាននាយកសាលា ២នាក់ មានសិស្ស ២៣០នាក់ (យុវជន ៩២នាក់)។

ភី អ ឌី បានដំណើរការសិក្ខាសាលាអភិវឌ្ឍន៍វិជ្ជាជីវៈចំនួន ៣វគ្គ ដល់គ្រូបង្រៀនទាំងអស់ដើម្បីពង្រឹងវិធីសាស្រ្តបង្រៀន ផលិតល្បែងសិក្សា និងសម្ភារៈបង្រៀនសម្រាប់ថ្នាក់រៀន ហើយសិក្ខាសាលាទាំងនោះបានផ្តោតលើ ការអនុវត្តល្អៗ បញ្ហាប្រឈម និងដំណោះស្រាយដែលបានជួបនៅក្នុងថ្នាក់រៀន ពិនិត្យឡើងវិញនូវវិធីសាស្រ្តបង្រៀនលើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាក្នុងថ្នាក់នីមួយៗ (ចាប់ពីថ្នាក់ទី ១ ដល់ ទី៦) និងការផលិតសម្ភារៈបង្រៀន និងរៀន។

នៅថ្ងៃទី១៦ ទី១៧ ខែមិថុនា ឆ្នាំ២០២៣ ភី អ ឌី បានសហការជាមួយការិយាល័យអប់រំស្រុកសំឡូតក្នុងការបើកវគ្គបណ្តុះបណ្តាលដល់គ្រូចំនួន ៤៨នាក់ ស្រីចំនួន២០នាក់ ដែលមកពីសាលាគោលដៅចំនួន៥ សាលានិងសាលាឧបសម្ព័ន្ធចំនួន៤សាលា។

នៅថ្ងៃទី២៥ ទី២៦ខែសីហា ឆ្នាំ២០២៣ ភី អី ឌី បានសហការជាមួយប្រធានការិយាល័អប់រំក្រុងប៉ៃលិនដើម្បីបើកវគ្គបណ្តុះបណ្តាលដល់គ្រូបង្រៀនចំនួន១៥ នាក់ ស្រី ៨នាក់ មកពីសាលាគោលដៅចំនួន៣សាលាដូចជា សាលាបឋមសិក្សាពេជ្រគីរី សាលាបឋមសិក្សាទឹកផុស និងសាលាបឋមសិក្សាអណ្តូងថ្ម ដែលមានប្រធានបទសំខាន់ៗមួយចំនួនដូចខាងក្រោម៖

- វិធីសាស្រ្តបង្រៀនកម្រិតបឋមសិក្សា
- ការរៀបចំតេស្តស្តង់ដាសម្រាប់វាស់វែងសមត្ថភាពសិស្សប្រចាំខែ
- វិធីសាស្រ្តបង្រៀនបែបបរិយាប័ន
- ការអនុវត្តន៍ការដាក់វិន័យបែបវិជ្ជមាន




## ២.១.៩ ការគាំទ្រសម្ភារៈបង្រៀន និងរៀន

អង្គការ ភី អ ឌី បានផ្ដល់សម្ភារៈបង្រៀន និងរៀនដល់សាលាគោលដៅចំនួន១០សាលា ដើម្បីគាំទ្រ និងបំពេញបន្ថែមសម្រាប់ការផលិតសម្ភារៈបង្រៀន និងរៀន រួមទាំងការតុបតែងថ្នាក់រៀនផងដែរ. សម្ភារៈទាំងនោះមានដូចជា៖ ក្រដាសកាតុង ក្រដាស A4 ក្រដាសពណ៌ A4 ហ្វឹតក្រដាស ហ្វឹតក្ដាខៀន កូល័រទាន ក្របប្លាស្ទិតសម្រាប់អ៊ុតក្រដាសកាតុង បន្ទាត់វែង ផ្ទាំងរូបភាពសម្រាប់តុបតែងថ្នាក់ សម្ភារៈសង្គ្រោះបឋម និងសាប៊ូដុំសម្រាប់លាងដៃផងដែរ។




## ២.១.១០ ការចុះសង្កេតថ្នាក់រៀន និងការវាយតម្លៃការបង្រៀន

នៅថ្ងៃទី២៥ ទី២៦ ខែកញ្ញា ឆ្នាំ២០២៣ ភី អ ឌី បានសហការជាមួយការិយាល័យអប់រំក្រុងប៉ៃលិនដើម្បីចុះសង្កេតថ្នាក់រៀនចំនួន ៩ថ្នាក់ និងបានធ្វើការវាយតម្លៃការបង្រៀនរបស់លោកគ្រូអ្នកគ្រូនៅសាលាបឋមសិក្សាទឹកផុស និងសាលាបឋមសិក្សាពេជ្រគីរី។

នៅថ្ងៃទី ២៦ ទី ២៧ ខែកញ្ញា និងថ្ងៃទី ០៣ ទី ០៤ ទី ០៥ ខែតុលា ឆ្នាំ 2023 ភី អ ឌី បានសហការជាមួយការិយាល័យអប់រំស្រុកសំឡូត ចុះត្រួតពិនិត្យថ្នាក់រៀនចំនួន៦ថ្នាក់នៅសាលាបឋមសិក្សាវាលធ្លា ទ្រុងខ្លា ដូនត្រីត មានជ័យ និងបឋមសិក្សាព្រៃរំចេក។ ការសង្កេត និងអធិការកិច្ចមានគោលបំណងវាស់ស្ទង់សមត្ថភាពបង្រៀនរបស់គ្រូបង្រៀន ការអនុវត្តវិធីសាស្ត្រសមស្រប និងផែនការមេរៀនដែលបានរៀបចំ។ ការសង្កេត និងអធិការកិច្ចបានផ្តោតទៅលើផ្នែកមួយចំនួនដូចជា (១) បរិយាកាសក្នុង

ថ្នាក់ដែលសុវត្ថិភាព និងការលើកទឹកចិត្តរបស់សិស្ស (២) ការគ្រប់គ្រងភារកិច្ចសម្រាប់សិស្សក្នុងថ្នាក់ (៣) រចនាសម្ព័ន្ធមេរៀន (៤) កិច្ចការរដ្ឋបាល (៥) ការបង្រៀន និងវិធីសាស្ត្រសិក្សា និង(៦) ការគ្រប់គ្រងថ្នាក់រៀន។




## ២.១.១១ ការប្រជុំគណៈកម្មាធិការសាលា គ្រូបង្រៀន និងអាណាព្យាបាលសិស្ស

នៅខែតុលា ឆ្នាំ ២០២៣ ភី អ ឌី បានធ្វើការជាមួយនាយកសាលា ដើម្បីរៀបចំ និងដឹកនាំការប្រជុំជាច្រើនជាមួយគណៈកម្មាធិការសាលាដូចជា៖ អ្នកទទួលបន្ទុកកិច្ចការស្ត្រីនិងកុមារ គ្រូបង្រៀន និងឪពុកម្ដាយសិស្ស ដើម្បីសិក្សាពីការសហការគ្នាល្អៗ បញ្ហាប្រឈមនានា និងដំណោះស្រាយល្អប្រសើរនៅពេលអនាគតយ៉ាងណាខ្លះ។

នៅថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០២៣ ភី អ ឌី បានដឹកនាំកិច្ចប្រជុំជាមួយគណៈកម្មាធិការគ្រប់គ្រងសាលារៀន ឪពុកម្ដាយសិស្ស លោកគ្រូ អ្នកគ្រូ និង អ្នកទទួលបន្ទុកកិច្ចការស្ត្រីនិងកុមារនៅសាលាបឋមសិក្សាដូនត្រីតដែលមានអ្នកចូលរួមចំនួន ៦៤ នាក់ (ស្រី ៣៧ នាក់) ។

ភី អ ឌី ក៏បានបើកកិច្ចប្រជុំចំនួន ២ ជាមួយគណៈកម្មាធិការគ្រប់គ្រងសាលារៀននៅសាលាបឋមសិក្សាភ្នំរ៉ៃ និងសាលាបឋមសិក្សាសុខសាន្ត ដើម្បីពង្រឹងការចូលរួមរបស់គណៈកម្មាធិការ និងមាតាបិតាជាមួយសាលាទាំងពីរ។ អ្នកចូលរួមប្រជុំមានចំនួន ៤៥ នាក់ (ស្រី ២២ នាក់)

ភី អ ឌី បានបើកវគ្គបណ្ដុះបណ្ដាលការចិញ្ចឹមកូនបែបវិជ្ជមានចំនួន ២ វគ្គ ដល់គណៈកម្មការគ្រប់គ្រងសាលារៀន ក្រុមយុវជន និងមាតាបិតានៅសាលាបឋមសិក្សាភ្នំរ៉ៃ និងសាលាបឋមសិក្សាសុខសាន្ត ដែលមានឪពុកម្ដាយចំនួន ៧៤នាក់ (ស្រី ៥៨នាក់) បានចូលរួមវគ្គបណ្ដុះបណ្ដាលនេះ។




## ២.១.១២ សិក្ខាសាលាស្តីពីសុខភាព និងអនាម័យ

នៅថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០២៣ ភី អ ឌី បានផ្តល់សាប៊ូដុំចំនួន ៤០០ដុំ ដល់សាលាបឋមសិក្សាគោលដៅចំនួន ៨ សាលា នៅសំឡូត ៥សាលា និងប៉ៃលិន ៣សាលា សម្រាប់ការលាងសម្អាតដៃ និងការធ្វើអនាម័យនៅសាលារៀន។ សាលានីមួយៗទទួលបានសាប៊ូដុំចំនួន ៥០ដុំ សម្រាប់១ឆ្នាំ។




ក្នុងឱកាសនោះ ភី អ ឌី បានសហការជាមួយមណ្ឌលសុខភាពឃុំតាសាញ ដើម្បីចែករំលែកប្រធានបទពីការការពារ និងការធ្វើអនាម័យសំខាន់ៗមួយចំនួនដូចជា ជំងឺគ្រុនឈាម ការធ្វើអនាម័យរាងកាយ អនាម័យចំណីអាហារ និងការយល់ដឹងអំពីអាហារូបត្ថម្ភដល់សិស្សចំនួន ៦២ នាក់ (សិស្សស្រី ៣៤ នាក់) នៅសាលាបឋមសិក្សាដូនត្រីត។




## ២.២ សកម្មភាពក្លឹបសិក្សានៅសាលាបឋមសិក្សា

នៅពាក់កណ្តាលខែឧសភា ឆ្នាំ២០២៣ ភី អ ឌី បានចាប់ផ្តើមអនុវត្តសកម្មភាពក្លឹបសិក្សាផ្សេងៗ នៅតាមសាលាគោលដៅស្រុកសំឡូត និងខេត្តប៉ៃលិនដែលមានសកម្មភាពក្លឹបសិក្សាដូចខាងក្រោម៖




### ២.២.១ ក្លឹបភាសាអង់គ្លេសសម្រាប់ក្មេងស្រី

នៅខែឧសភា ឆ្នាំ 2023 ភី អ ឌី បានបន្តធ្វើការជាមួយនាយកសាលាគោលដៅទាំង៦សាលា ដើម្បីជ្រើសរើសគ្រូមកដឹកនាំក្លឹបភាសាអង់គ្លេសនៅសំឡូត និងប៉ៃលិន។ មានក្លឹបភាសាអង់គ្លេសចំនួន ៦ ក្លឹប (៤ នៅសំឡូត និង ២ នៅប៉ៃលិន)។ ក្លឹបភាសាអង់គ្លេសសិក្សាចំនួន ៦ ម៉ោងក្នុងមួយសប្តាហ៍ និង ១ ឬ ២ ម៉ោងក្នុងមួយថ្ងៃ។ ភី អ ឌី បានផ្តល់ជំនួយឧបត្ថម្ភដល់គ្រូដឹកនាំក្លឹប និងផ្តល់សម្ភារៈសម្រាប់សកម្មភាពក្នុងថ្នាក់រៀន។ ភី អ ឌី ក៏បានផ្តល់ការកសាងសមត្ថភាពដល់គ្រូដឹកនាំក្លឹប ដើម្បីបង្កើនជំនាញបង្រៀនរបស់ពួកគេ ដែលរួមមានជំនាញអាន ការសរសេរ អក្ខរាវិរុទ្ធ និងជំនាញនិយាយ។ កាលវិភាគក្លឹបអង់គ្លេសត្រូវបានកំណត់នៅក្រៅម៉ោងសិក្សា ដូច្នេះសិស្សអាចសិក្សាម៉ោងរដ្ឋដូចធម្មតា។ តារាងខាងក្រោមបង្ហាញពីចំនួនសិស្សនៅក្នុងក្លឹបនីមួយៗ៖

| សាលាគោលដៅស្រុកសំឡូត | ក្លឹបភាសាអង់គ្លេសសម្រាប់ក្មេងស្រី | | ផ្សេងៗ |
|---|---|---|---|
| | សមាជិកសរុប | ស្រី | |
| សាលាបឋមសិក្សាទ្រុងខ្លា | 22 | 22 | |
| សាលាបឋមសិក្សាវាលធ្លា | 18 | 18 | |
| សាលាបឋមសិក្សាដូនត្រីត | 20 | 20 | |
| សាលាបឋមសិក្សាមានជ័យ | 13 | 13 | |
| សរុបចំនួនសិស្សនៅស្រុកសំឡូត | 73 | 73 | |
| សាលាគោលដៅនៅប៉ៃលិន | ក្លឹបភាសាអង់គ្លេសសម្រាប់ក្មេងស្រី | | ផ្សេងៗ |
| | សមាជិកសរុប | ស្រី | |
| សាលាបឋមសិក្សាពេជ្រគីរី | 16 | 16 | |
| សាលាបឋមសិក្សាទឹកផុស | 27 | 27 | |
| សរុបចំនួនសិស្សនៅប៉ៃលិន | 43 | 43 | |
| សរុបចំនួនសិស្សនៅស្រុកសំឡូត និងប៉ៃលិន | 116 | 116 | |





### ២.២.២ ក្លឹបកីឡាសម្រាប់ក្មេងស្រី

ភី អ ឌី បានបន្តការគាំទ្រលើការអនុវត្តសកម្មភាពក្លឹបកីឡានៅសាលាគោលដៅចំនួន ៨ នៅសំឡូត (សាលាបឋមសិក្សាដូនត្រឹត វាលធ្នា សាលាបឋមសិក្សាទ្រុងខ្លា) និងប៉ៃលិន (សាលាបឋមសិក្សាពេជ្រគិរី ទឹកផុស សាលាបឋមសិក្សាអណ្តូងថ្ម) ។

នៅខែឧសភា ឆ្នាំ ២០២៣ ភី អ ឌី បានធ្វើការជាមួយសាលារៀនគោលដៅដើម្បីចាប់ផ្តើមក្លឹបកីឡាសម្រាប់សកម្មភាពក្មេងស្រី។ ក្លឹបកីឡានីមួយៗមាន ២ ម៉ោងក្នុងមួយសប្តាហ៍នៅខាងក្រៅម៉ោងសិក្សារដ្ឋ។ ក្រុមក្មេងស្រីបាននិយាយថា "ពួកយើងបានល្អប្រសើរឡើងនូវកម្លាំងរាងកាយរបស់យើង មានភាពបត់បែនជាងមុន មិត្តភក្តិកាន់តែច្រើន មានភាពសកម្ម និងមិនសូវឈឺ"។

ខាងក្រោមនេះគឺជាចំនួនក្លឹបកីឡា។

| សាលាគោលដៅនៅស្រុកសំឡូត | ក្លឹបកីឡាសម្រាបក្មេងស្រី | | ផ្សេងៗ |
|---|---|---|---|
| | សមាជិកសរុប | ស្រី | |
| សាលាបឋមសិក្សាទ្រុងខ្លា | 26 | 26 | |
| សាលាបឋមសិក្សាវាលធ្នា | 16 | 16 | |
| សាលាបឋមសិក្សាដូនត្រឹត | 18 | 18 | |
| សាលាបឋមសិក្សាភ្នំរ៉ៃ | 20 | 20 | |
| សាលាបឋមសិក្សាសុខសាន្ត | 20 | 20 | |
| សរុបសិស្សស្រីនៅសំឡូត | 100 | 100 | |
| សាលាគោលដៅប៉ៃលិន | ក្លឹបកីឡាសម្រាប់ក្មេងស្រី | | ផ្សេង |
| | សមាជិកសរុប | ស្រី | |
| សាលាបឋមសិក្សាពេជ្រគិរី | 23 | 23 | |
| សាលាបឋមសិក្សាទឹកផុស | 28 | 28 | |
| សាលាបឋមសិក្សាអណ្តូងថ្ម | 26 | 26 | |
| សរុបចំនួនសិស្សនៅប៉ៃលិន | 77 | 77 | |
| សរុបចំនួនសិស្សនៅស្រុកសំឡូត និងប៉ៃលិន | 177 | 177 | |

#### ២.២.២.១ ការផ្តល់សម្ភារៈសម្រាប់ក្លឹបកីឡា

អង្គការ ភី អ ឌី បានផ្តល់សម្ភារកីឡាដល់ក្លឹបកីឡាចំនួន ៨ (៥ នៅសំឡូត និង ៣ នៅប៉ៃលិន)។ សម្ភារៈរួមមាន បាល់ទាត់ បាល់ទះ កញ្ចែ សម្ភារៈហ្វឹកហាត់ សំណាញ់បាល់ទាត់ និងបានផ្តល់ឯក

សណ្ឋានកីឡាចំនួន ២ ឈុត ដល់ថ្នាក់ដឹកនាំកីឡា និង ១ ឈុត ដល់សមាជិកកីឡានៅសាលាបឋមសិក្សាភ្នំរ៉ៃ និងសាលាបឋមសិក្សាសុខសាន្ត។ លើសពីនេះ ភី អ ឌី ក៏បានផ្តល់សម្ភារៈកីឡាដូចជា បាល់ទាត់ បាល់ទះ ដល់សាលាបឋមសិក្សាភ្នំរ៉ៃ និងសុខសាន្ត។ តាមរយៈជំនួយសម្ភារៈទាំងនេះ ភី អ ឌី ជឿជាក់ថា ក្លឹបកីឡាទាំងអស់អាចមានសម្ភារៈគ្រប់គ្រាន់សម្រាប់ការហ្វឹកហាត់របស់ពួកគេ។




### ២.២.២.២ វគ្គសិក្ខាសាលារំលឹកដល់គ្រូដឹកនាំក្លឹបកីឡា

នៅថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០២៣ និងថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០២៣ ភី អ ឌី បានធ្វើការបណ្តុះបណ្តាលរំលឹកឡើងវិញដល់គ្រូដឹកនាំកីឡាចំនួន៨ នាក់មកពីក្លឹបកីឡាចំនួន ៦ នៅស្រុកសំឡូត និងខេត្តប៉ៃលិន។ នេះជាការបណ្តុះបណ្តាលបច្ចេកទេសថ្មីសម្រាប់គ្រូដឹកនាំក្លឹបកីឡា ដើម្បីបំពេញជំនាញបច្ចេកទេសក្នុងកីឡាបាល់ទាត់ និងបាល់ទះ ដើម្បីឱ្យពួកគេមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបណ្តុះបណ្តាលក្រុមកីឡានារីនៅតាមសាលាគោលដៅរបស់ភី អ ឌី។ លើសពីនេះ ក៏មានវគ្គបណ្តុះបណ្តាលចំនួន៣វគ្គទៀតដល់គ្រូដឹកនាំក្លឹបកីឡានៅសាលាភ្នំរ៉ៃ និងសាលាសុខសាន្ត ស្តីពីរបៀបដឹកនាំសកម្មភាពកីឡា និងបានផ្តល់សិក្ខាសាលាអប់រំកាយដល់លោកគ្រូអ្នកគ្រូចំនួន ១៤ នាក់ (ស្រី ៤នាក់) ។





### ២.២.២.៣ សកម្មភាពហ្វឹកហាត់ប្រចាំសប្តាហ៍

ក្លឹបកីឡាសម្រាប់ក្មេងស្រីត្រូវបានដំណើរការជាទៀងទាត់នៅថ្ងៃធ្វើការក្នុងអំឡុងពេលម៉ោងទំនេរពីសាលារដ្ឋ។ ក្លឹបកីឡាសម្រាប់ក្មេងស្រីមានពេល ២ ម៉ោងក្នុងមួយសប្តាហ៍សម្រាប់ការហ្វឹកហាត់ និងអនុវត្តជំនាញកីឡារបស់ពួកគេ។ ពេញមួយឆ្នាំនៃការហ្វឹកហ្វឺន ក្រុមក្មេងស្រីបានសិក្សាអំពីសារៈ

សំខាន់នៃស្មារតីក្រុម ការគ្រប់គ្រងបាល់ បញ្ជូនបាល់ ជំនាញវាយបក ជំនាញបញ្ជូនបាល់ និងការលើទីលាន។

| | |
|---|---|
|  |  |

### ២.២.២.៤ ការចូលរួមព្រឹត្តការណ៍ប្រកួតកីឡារបស់ក្លឹបកីឡាសម្រាប់ក្មេងស្រី

នៅថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ ២០២៣ ភី អ ឌី បានឧបត្ថម្ភដល់កីឡាការិនីចំនួន ៤៥ នាក់ និងគ្រូដឹកនាំចំនួន ៩ នាក់ សម្រាប់ថ្លៃអាហារ និងការមធ្យោបាយធ្វើដំណើរដល់ក្រុមបាល់ទាត់កុមារីមកពីសាលាបឋមសិក្សាទ្រុងខ្លា និងសាលាបឋមសិក្សាដូនត្រឹត ដើម្បីចូលរួមការប្រកួតបាល់ទាត់នៅថ្នាក់ស្រុក ជាលទ្ធផល ក្រុមកីឡាមកពីសាលាបឋមសិក្សាទ្រុងខ្លាទទួលបានចំណាត់ថ្នាក់លេខពីរ។ នៅថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០២៣ កីឡានារីនៃសាលាបឋមសិក្សាទ្រុងខ្លាបានទទួលបានចំណាត់ថ្នាក់លេខ ១ ក្នុងកម្មវិធីសម្ពោធ និងប្រគល់ទីលានកីឡាបាល់ទាត់ដល់សាលាបឋមសិក្សាទ្រុងខ្លា ហើយកីឡានារីមកពីសាលាបឋមសិក្សាវាលថ្នាទទួលបានចំណាត់ថ្នាក់លេខ ២ផងដែរ។

| | |
|---|---|
|  |  |
|  |  |

### ២.២.៣ ក្លឹបបរិស្ថានសម្រាប់ក្មេងស្រី

នៅឆ្នាំ ២០២៣ ភី អ ឌី បានបន្តដំណើរគាំទ្រក្លឹបបរិស្ថាន នៅក្នុងសាលាគោលដៅចំនួន ៨ នៅសំឡូត (សាលាបឋមសិក្សាដូនត្រីត វាលធ្លា ទ្រងខ្លា មានជ័យ ភ្នំរ៉ៃ និងសុខសាន្ត ) និងប៉ៃលិន (សាលាបឋមសិក្សាពេជ្រគីរី ទឹកផុស)។ ក្លឹបបរិស្ថាននីមួយៗសម្រាប់ក្មេងស្រីមាន ២ ម៉ោងក្នុងមួយសប្តាហ៍ ដើម្បីសិក្សានៅខាងក្រៅម៉ោងរដ្ឋ។ ក្លឹបបរិស្ថានបានសិក្សាពីប្រធានបទនៃការលើកកម្ពស់ការអភិរក្សសត្វព្រៃ ទឹក ព្រៃឈើ និងគ្រោះថ្នាក់នៃការបំពុលបរិស្ថាន។ ខាងក្រោមនេះជាចំនួនក្លឹបបរិស្ថាន និងចំនួនសិស្សក្លឹបៈ

| សាលាគោលដៅស្រុកសំឡូត | ក្លឹបបរិស្ថានសម្រាប់ក្មេងស្រី | | ផ្សេងៗ |
|---|---|---|---|
| | សមាជិកសរុប | ស្រី | |
| សាលាបឋមសិក្សាទ្រងខ្លា | 16 | 16 | |
| សាលាបឋមសិក្សាវាលធ្លា | 13 | 13 | |
| សាលាបឋមសិក្សាដូនត្រីត | 15 | 15 | |
| សាលាបឋមសិក្សាមានជ័យ | 16 | 16 | |
| សាលាបឋមសិក្សាភ្នំរ៉ៃ និងសុខសាន្ត | 42 | 42 | 19 Por |
| សរុបចំនួនសិស្សនៅសំឡូត | 102 | 102 | |
| សាលាគោលដៅប៉ៃលិន | ក្លឹបបរិស្ថានសម្រាប់ក្មេងស្រី | | ផ្សេងៗ |
| | សមាជិកសរុប | ស្រី | |
| សាលាបឋមសិក្សាពេជ្រគីរី | 23 | 23 | |
| សាលាបឋមសិក្សាទឹកផុស | 13 | 13 | |
| សរុបចំនួនសិស្សនៅប៉ៃលិន | 36 | 36 | |
| សរុបចំនួនសិស្សនៅសំឡូត និងប៉ៃលិន | 138 | 138 | |

#### ២.២.៣.១ ការផ្តល់សម្ភារៈសម្រាប់ក្លឹបបរិស្ថាន

អង្គការ ភី អ ឌី បានបន្តគាំទ្រសម្ភារៈដល់ក្លឹបបរិស្ថានចំនួន ៨ក្លឹបសិក្សា នៅសំឡូតចំនួន ៦ និង ២ក្លឹបទៀតនៅប៉ៃលិន សម្រាប់អ្នកដឹកនាំក្លឹប និងសមាជិកក្លឹបទាំងអស់ប្រើប្រាស់ដើម្បីអនុវត្តសកម្មភាពនេះ។ សម្ភារប្រើប្រាស់រួមមាន ក្រដាស់កាតុងទន់ និងរឹង ហ្វឹតសរសេរក្រដាស និងកូល័រជាត់ ស្កុតថ្លា ក្តារខៀន ក្រដាស A4 និងស្កុតក្រដាស។ លើសពីនេះទៅទៀត ភី អ ឌី ក៏បានផ្តល់ឯកសណ្ឋានរបស់ក្លឹបបរិស្ថានសម្រាប់អ្នកដឹកនាំក្លឹប និងសមាជិកម្នាក់មួយឈុតផងដែរ។

 

### ២.២.៣.២ សិក្ខាសាលាសម្រាប់អ្នកដឹកនាំក្លឹបបរិស្ថាន

នៅថ្ងៃទី ២៨ ខែសីហា ឆ្នាំ ២០២៣ ភី អ ឌី បានធ្វើសិក្ខាសាលារំលឹកសម្រាប់អ្នកដឹកនាំក្លឹបបរិស្ថាន អំពីរបៀបដំណើរការក្លឹប ជំហាន និងលំហូរនៃមេរៀនដែលមានសារៈសំខាន់ដើម្បីបង្រៀន ដល់សិស្សក្លឹបបរិស្ថាន និងពិនិត្យមើលគោលបំណងនៃ ការអនុវត្តក្លឹបបរិស្ថានសម្រាប់ក្មេងស្រី។ ក្រៅពីនេះ ភី អ ឌី បានបណ្តុះបណ្តាលចំនួន ៤វគ្គទៀតដល់អ្នកដឹកនាំក្លឹបបរិស្ថាននៅភ្នំរ៉ៃ និង សុខសាន្ត ស្តីពីបរិស្ថាន និងរបៀបដំណើរការក្លឹប ។

### ២.២.៣.៣ ការដំណើរការក្លឹបបរិស្ថានប្រចាំសប្តាហ៍

ភី អ ឌី បានដំណើរការក្លឹបបរិស្ថាន ២ ម៉ោងក្នុងមួយសប្តាហ៍។ ក្លឹបបរិស្ថានមានមេរៀនតែ 2 ប៉ុណ្ណោះដែលត្រូវបានជ្រើសរើសពីមេរៀនទាំងមូលនៅក្នុងសៀវភៅគោលដើម្បីបង្រៀនពេញមួយឆ្នាំ។ នៅឆ្នាំ ២០២៣ ក្លឹបបរិស្ថានបានសិក្សាអំពីជីវចម្រុះ សត្វព្រៃ និងព្រៃឈើ ហើយរួមទាំងការគ្រប់គ្រងកាកសំណល់នៅក្នុងសាលារៀន និងនៅផ្ទះរបស់ពួកគេ។ ជាងនេះទៅទៀតអ្នកដឹកនាំក្លឹបបានបង្រៀនកុមារីឱ្យអនុវត្តការកែច្នៃដបទឹកសុទ្ធដែលបានប្រើរួច និងសម្ភារៈផ្លាស្ទិចដើម្បីប្រើប្រាស់តុបតែងថ្នាក់ និងការប្រើប្រាស់ផ្សេងៗ។

 

### ២.២.៣.៤ កម្មវិធីលេងកម្សាន្តរបស់ក្លឹបបរិស្ថាន

អង្គការ ភី អ ឌី បានគាំទ្រសាលាបឋមសិក្សាជូនត្រឹតដើម្បីអនុវត្ត រៀបចំព្រឹត្តិការណ៍លេងកម្សាន្តប្រចាំឆ្នាំរបស់ក្លឹបបរិស្ថានសម្រាប់ក្មេងស្រី។ កម្មវិធីនេះមានគោលបំណងលើកកម្ពស់អោយកុមារីមាន

ទំនុកចិត្តលើខ្លួនឯង ដើម្បីចែករំលែក និងលើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃការរក្សាដើមឈើ ការសង្គ្រោះសត្វព្រៃ ការរស់នៅក្នុងបរិស្ថានបៃតង និងអនាម័យ ការការពារសត្វព្រៃ និងព្រៃឈើនៅក្នុងសហគមន៍របស់ពួកគេ។ ក្នុងកម្មវិធីលេងកម្សាន្តនៅសាលាបឋមសិក្សាដូនត្រឹត ក្រុមកុមារីក្លឹបបរិស្ថានបានធ្វើបទបង្ហាញអំពីសារៈសំខាន់នៃការមានបរិស្ថានបៃតងដល់សិស្សានុសិស្សចំនួន ១៥០ នាក់ និងឪពុកម្ដាយចំនួន ៥០ នាក់។ បន្ទាប់មកពួកគេបានសម្ដែងរឿងខ្លីលើប្រធានបទ "ការថែរក្សាដើមឈើ និងការដាំដើមឈើ គឺជាការជួយសង្គ្រោះជីវិតយើង"។






## ២.២.៤ សកម្មភាពបណ្ណាល័យ និងក្លឹបអានសម្រាប់ក្មេងស្រី

អង្គការ ភី អ ឌី បានបន្តគាំទ្រក្លឹបអំណានក្នុងសាលាគោលដៅចំនួន ៥ នៅសំឡូត (សាលាបឋមសិក្សាដូនត្រឹត ទ្រុងខ្លា ភ្នំរ៉ៃ សុខសាន្ត និងសាលាបឋមសិក្សាមានជ័យ) និងប៉ៃលិន (សាលាបឋមសិក្សាពេជ្រគីរី និងសាលាបឋមសិក្សាទឹកផុស)។ ក្លឹបអាននីមួយៗមានពេល ២ ម៉ោងក្នុងមួយសប្ដាហ៍ដើម្បីសិក្សាក្រៅម៉ោងរដ្ឋ។ ចំណាំ៖ សាលាបឋមសិក្សាទាំងពីរមិនមានបណ្ណាល័យទេ អង្គការភី អ ឌី ស្នើឱ្យនាយកសាលារៀបចំបន្ទប់មួយក្លាយជាបណ្ណាល័យនៅសាលាបឋមសិក្សាភ្នំរ៉ៃ និងសុខសាន្តដោយប្រើឡាំងដែកសម្រាប់រក្សាទុកសៀវភៅរឿងដែល ភី អ ឌី ផ្ដល់ជូនគ្រូសម្រាប់អាន។

ខាងក្រោមគឺជាចំនួននៃការអានក្លឹបកុមារី

| សាលាគោលដៅស្រុកសំឡូត | ក្លឹបអានសម្រាបក្មេងស្រី | | ផ្សេងៗ |
|---|---|---|---|
| | សមាជិកសរុប | ស្រី | |
| សាលាបឋមសិក្សាទ្រុងខ្លា | 22 | 22 | |

| | | | |
|---|---|---|---|
| សាលាបឋមសិក្សាដូនត្រីត | 15 | 15 | |
| សាលាបឋមសិក្សាមានជ័យ | 15 | 15 | |
| សាលាបឋមសិក្សាភ្នំរ៉ៃ និងសុខសាន្ត | 40 | 40 | 16 Por |
| សរុបចំនួននៅសំឡូត | 92 | 92 | |
| សាលាគោលដៅប៉ៃលិន | ក្លឹបអានសម្រាបក្មេងស្រី | | ផ្សេងៗ |
| | សមាជិកសរុប | ស្រី | |
| សាលាបឋមសិក្សាពេជ្រគីរី | 15 | 15 | |
| សាលាបឋមសិក្សាទឹកផុស | 13 | 13 | |
| សរុបចំនួននៅប៉ៃលិន | 28 | 28 | |
| សរុបចំនួននៅសំឡូត និងប៉ៃលិន | 120 | 120 | |

### ២.២.៤.១ ការគាំទ្រសម្ភារៈសម្រាប់ដំណើរការក្លឹបអាន

អង្គការ ភី អ ឌី បានឧបត្ថម្ភសម្ភារៈអានដល់គ្រូដឹកនាំក្លឹបអានចំនួន ៥ក្លឹបនៅសំឡូត និង ២ក្លឹបនៅប៉ៃលិន ដើម្បីប្រើប្រាស់ក្នុងការដំណើរការជាក់ស្តែង។ សម្ភារៈទាំងនោះមានដូចជា៖ ក្រដាសផ្ទាំងធំ ហ្វឺតសរសេរក្រដាស/ក្តាខៀន និងកូល័រឈើជាដើម។ ភី អ ឌី ក៏បានផ្តល់សៀវភៅរឿងចំនួន ៣៣៣ក្បាលសម្រាប់សាលាបឋមសិក្សាចំនួន ៣សាលា (សាលាបឋមសិក្សាដូនត្រីត វាលធ្នា និងសាលាបឋមសិក្សាព្រៃរំចេក) ដើម្បីរក្សាទុកក្នុងបណ្ណាល័យ និងការិយាល័យសាលា ដើម្បីឱ្យសិស្សអានពេលសម្រាក។ លើសពីនេះ ភី អ ឌី បានផ្តល់សៀវភៅនិទានរឿង ៣៥៤ក្បាល ដល់បណ្ណាល័យភ្នំរ៉ៃ និងសុខសាន្ត រួមទាំងផ្តល់សម្ភារៈដល់ក្លឹបអានដូចជា ក្រដាសកាតុង ផ្ទាំងក្រដាស ហ្វឺតសរសេរក្រដាសក្តាខៀន ស្កុតក្រដាស ក្រដាស A4 និងក្រដាសពណ៌ A4 (២ ដងក្នុងមួយឆ្នាំ) និងសៀវភៅកត់ត្រាចំនួន ៣ ក្បាលសម្រាប់សមាជិកម្នាក់ៗនៅភ្នំរ៉ៃ និងសុខសាន្ត។





### ២..២.៤.២ សិក្ខាសាលាសម្រប់អ្នកដឹកនាំក្លឹបអាន

ក្រុមការងារផ្នែកអប់រំរបស់ភី អ ឌី បានចុះអង្កេតផ្ទាល់ដល់ការអនុវត្តក្លឹបអាននៅសំឡូត និងប៉ៃលិន ដើម្បីកែលម្អចំណុចខ្វះខាតនិង សម្រាប់ផ្តល់ជំនួយបច្ចេកទេសបន្ថែមទៀត។ តាមរយៈការ

សង្កេតពីក្រុមការងារផ្នែកអប់រំ ភី អ ឌី បានរកឃើញចំណុចត្រូវកែលម្អមួយចំនួន ដូចជាទម្រង់ក្លឹបអានបច្ចេកទេសពិភាក្សាអំពីតម្លៃអប់រំនៃរឿង ការវិភាគតួអង្គនៃរឿង -ល-។

ក្រុមការងារអប់រំ ភី អ ឌី បានរៀបចំផែនការសកម្មភាពដោយផ្អែកលើលទ្ធផល និងបានបើកសិក្ខាសាលាបំប៉នលើចំណុចខ្វះខាតដល់អ្នកដឹកនាំក្លឹបអំណានទាំង ៩នាក់នៅសំឡូត និងប៉ៃលិននៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ ស្ដីពីការកែលម្អឡើងវិញនូវក្របខ័ណ្ឌបច្ចេកទេស និងគោលបំណងនៃក្លឹបអាន។ ក្រៅពីនេះ ភី អ ឌីក៏មានវគ្គបណ្ដុះបណ្ដាលចំនួន ៤វគ្គទៀតដល់បណ្ណារក្ស អំពីរបៀបដឹកនាំក្លឹបអំណាន និងសកម្មភាពបណ្ណាល័យដល់លោកគ្រូ អ្នកគ្រូ ១៤ នាក់ (ស្រី ៤នាក់) និងនាយកសាលានៅសាលាបឋមសិក្សាភ្នំរ៉ៃ និងសាលាបឋមសិក្សាសុខសាន្ត អំពីរបៀបអានរឿងក្នុងថ្នាក់ និងរបៀបសរសេរសាច់រឿងខ្លីៗ ជាពិសេស ភី អ ឌី បានសហការជាមួយលោកគ្រូអ្នកគ្រូនៅថ្នាក់ទី ៤-៦ ដើម្បីណែនាំរបៀបសរសេររឿងខ្លីសម្រាប់សិស្សានុសិស្សទាំងអស់នៅថ្នាក់ទី ៤-៦ នៅសាលាបឋមសិក្សាភ្នំរ៉ៃ និងសាលាបឋមសិក្សាសុខសាន្តដែលមានសិស្សចូលរួមសរុបចំនួន ៨០នាក់ (ស្រី ៤៣នាក់)។





### ២.២.៤.៣ សកម្មភាពប្រចាំសប្ដាហ៍របស់ក្លឹបអាន

ការអានមានសារៈសំខាន់ខ្លាំងណាស់ក្នុងការបង្កើតការផ្លាស់ប្ដូរជាវិជ្ជមាន និងទម្លាប់ល្អសម្រាប់សិស្សានុសិស្សនៅក្នុងសាលារដ្ឋ។ ភី អ ឌី បានផ្ដល់ការគាំទ្រដល់អ្នកដឹកនាំក្លឹបអាន ដើម្បីដំណើរការក្លឹបអានសម្រាប់សិស្សស្រី ដើម្បីបង្កើតទម្លាប់អានសៀវភៅពីសិស្សវ័យក្មេង។ ការអនុវត្តក្លឹបអានទាំងនេះ អ្នកដឹកនាំការអានបានដឹកនាំសមាជិកអានរបស់ពួកគេឱ្យអានសៀវភៅរឿងឱ្យបានទៀងទាត់យ៉ាងហោចណាស់ ១ ទៅ ២ រឿងក្នុងមួយសប្ដាហ៍។ មុននឹងអាន អ្នកដឹកនាំក្លឹបអានបានបង្កើតនូវសំណួរដែលបំផុសគំនិត និងបញ្ចេញគំនិតពីសមាជិក។ អ្នកដឹកនាំចាប់ផ្ដើមអានសាច់រឿងទាំងមូល។បន្ទាប់ពីអានចប់ អ្នកដឹកនាំបានបែងចែកពួកគេជាក្រុមសម្រាប់ធ្វើការពិភាក្សាអំពីតម្លៃអប់រំនៃរឿង តួអង្គសំខាន់ៗ សង្ខេបសាច់រឿង និងបង្ហាញដល់ក្រុមទាំងមូល។




### ២.២.៤.៤ ការចូលរួមក្នុងព្រឹត្តិការណ៍ទិវាអំណានជាតិ

នៅឆ្នាំ ២០២៣ ភី អ ឌី បានបរិច្ចាគសម្ភារៈមួយចំនួនដូចជា សៀវភៅកត់ត្រា និងប៊ិច ដល់មន្ទីរអប់រំខេត្តបាត់ដំបង ក្នុងឱកាសទិវាអំណានជាតិ។ ការរួមចំណែកជាសម្ភារៈនេះបានបង្ហាញពីសារៈសំខាន់នៃការចូលរួមជាមួយរដ្ឋាភិបាលក្នុងការផ្តល់រង្វាន់ដល់សិស្សពូកែក្នុងអំឡុងពេលប្រកួតប្រជែងរបស់ពួកគេ ជាពិសេសនេះបង្ហាញពីកិច្ចសហការយ៉ាងជិតស្និទ្ធ និងសកម្មក្នុងនាមជាដៃគូអប់រំនៅក្នុងខេត្តបាត់ដំបង។ ភី អ ឌី បានចូលរួមសៀវភៅសរសេរចំនួន ៥០ក្បាល និងប៊ិកចំនួន១០០ ដើម។





### ២.២.៥ សកម្មភាពបំណិនជីវិត និងសួនបន្លែសាលារៀន

សកម្មភាពបំណិនជីវិត និងសួនបន្លែក្នុងសាលាមានសារៈសំខាន់សម្រាប់សិស្សានុសិស្សគ្រប់លំដាប់ថ្នាក់ក្នុងសាលារដ្ឋ ឬឯកជន។ នៅឆ្នាំ ២០២៣ ភី អ ឌី បន្តផ្តល់ការគាំទ្រមួយចំនួនដល់សាលាបឋមសិក្សាចំនួន ៨ ដើម្បីអនុវត្តសកម្មភាពទាំងនេះ។ សាលារៀនគោលដៅភី អ ឌី ភាគច្រើនបានធ្វើសួនបន្លែនៅក្នុងសាលារបស់ពួកគេដែលជាផ្នែកមួយនៃការអនុវត្តបំណិនជីវិតរបស់ពួកគេ ដើម្បីឱ្យសិស្សអាចរៀនអំពីជំនាញដាំដុះ និងបច្ចេកទេសដាំបន្លែទាំងក្នុងសាលា និងផ្ទះរបស់ពួកគេ។ ភី អ ឌី បានផ្តល់គ្រាប់ពូជបន្លែចំរុះចំនួន ៣កញ្ចប់ដល់សាលាគោលដៅចំនួន៤សាលា (សាលាបឋមសិក្សាមានជ័យ ដូនត្រឹត ទ្រុងខ្លា និងទឹកផុស)










## ២.៣. គម្រោងនៅវិទ្យាល័យ

នៅខែមិថុនា ឆ្នាំ២០២៣ ភី អ ឌី បានបន្តគាំទ្រដល់វិទ្យាល័យសំឡូតលើការទិញសម្ភារៈ STEM ដែលមានវត្ថុធាតុដើមមួយចំនួនសម្រាប់ការធ្វើពិសោធន៍គីមីសាស្ត្រ ហើយ ភី អ ឌី ក៏បានបង្កើតក្លឹបសិក្សាសាកល្បងចំនួន ២ក្លឹបទៀត គឺក្លឹបកុំព្យូទ័រសម្រាប់សិស្សស្រី និងក្លឹបភាសាអង់គ្លេសសម្រាប់សិស្សស្រី។






### ២.៣.១ ក្លឹបកុំព្យូទ័រសម្រាប់សិស្សស្រី

អង្គការ ភី អ ឌីបានគាំទ្រការបង្កើតក្លឹបកុំព្យូទ័រនៅក្នុងវិទ្យាល័យសំឡូតដែលមានសិស្សស្រីចំនួន 20 នាក់ បានរៀនពីជំនាញកុំព្យូទ័រជាមូលដ្ឋានដែលជាជំហានស្ពានមួយមុនពេលចូលសកលវិទ្យាល័យ។ ភី អ ឌី បានផ្តល់ប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់គ្រូបង្រៀនកុំព្យូទ័រ ២ ម៉ោងក្នុងមួយសប្តាហ៍។ កម្មវិធី

កុំព្យូទ័រសាកល្បងបានបង្រៀនពីជំនាញវាយអត្ថបទ និងមូលដ្ឋានគ្រឹះនៃ Microsoft office (word, excel, និង power point)។




## ២.៣.២ គម្រោងSTEM (ការពិសោធន៍គីមីសាស្ត្រ)

អង្គការ ភី អ ឌី បានគាំទ្រដល់វិទ្យាល័យសំឡូតក្នុងការអនុវត្តសកម្មភាព STEM ជាមួយសិស្សស្រីចំនួន ១០នាក់ ហើយបានផ្តល់សម្ភារៈ និងវត្ថុធាតុដើមដូចមានក្នុងតារាងខាងក្រោម៖

| ឧបករណ៍ ឬសារធាតុ | បរិមាណ | ឧបករណ៍ ឬសារធាតុ | បរិមាណ |
|---|---|---|---|
| Laptop | 1 | $Na_2S_2O_3.5H_2O$ | 500g |
| KI | 50g | $Pb(NO)_3$ | 500g |
| $KMnO_4$ | 500g | $H_2SO_4$ | 1L |
| $H_2C_2O_4.2H_2O$ | 500g | សារធាតុផ្សំសាប៊ូ | ១ឈុត |

ជាលទ្ធផលនៅឆ្នាំ ២០២៣ សិស្សបាលផលិតសាប៊ូលាងចានបានចំនួន៨០លីត្រ ហើយបានចែកគ្នាប្រើប្រាសាកល្បង ហើយលក់ និងផ្សព្វផ្សាយដល់សហគមន៍ ដើម្បីបានថវិកាទិញសម្ភារៈផលិតបន្ត។




## ២.៣.៣ គម្រោងក្លឹបភាសាអង់គ្លេសសម្រាប់ក្មេងស្រី

អង្គការ ភី អ ឌី បានគាំទ្រការសាកល្បងថ្នាក់ភាសាអង់គ្លេសសម្រាប់សិស្សស្រីចំនួន ៤៥ នាក់ នៅវិទ្យាល័យសំឡូតក្នុងឆ្នាំ ២០២៣ ក្នុងគោលបំណងផ្តល់ឱកាសដល់សិស្សស្រីដែលមកពីគ្រួសារក្រីក្រ ហើយស្នាក់នៅអន្តេវាសិកដ្ឋានបានរៀនភាសាអង់គ្លេសដូចក្មេងស្រីផ្សេងទៀតដែលមកពីគ្រួសារ

ដែលប្រសើរជាង។ កម្មវិធិសាកល្បនេះនឹងជួយសិស្សឱ្យពង្រឹងចំណេះដឹងភាសាអង់គ្លេសរបស់ពួកគេជាផ្នែកមួយនៃការផ្សារភ្ជាប់ និងធ្វើឱ្យពួកគេមានភាពងាយស្រួលក្នុងការរៀន ឬស្រាវជ្រាវពីវិទ្យាល័យរហូតដល់សាកលវិទ្យាល័យ។






## ២.៤. គម្រោងអាហារូបករណ៍សម្រាប់សិស្សស្រី

នៅឆ្នា ២០២៣ ភី អ ឌី បានបន្តផ្តល់ជំនួយអាហារូបករណ៍ដល់សិស្សស្រីចំនួន ២០ នាក់នៅស្រុកសំឡូត និងប៉ៃលិនពីគម្រោងចាស់ និងបន្ថែមសិស្សអាហារូបករណ៍ចំនួន ២១ នាក់ (សិស្សជនជាតិព័រ ១២នាក់) នៅនៅភូមិភ្នំរ៉ៃ និងសុខសាន្ត។ គម្រោងអាហារូបករណ៍សម្រាប់សិស្សស្រីមានគោលបំណងក្នុងការលើកកម្ពស់ និងជួយសម្រួលដល់សិស្សស្រីមកពីគ្រួសារក្រីក្រឱ្យមានឱកាសស្មើគ្នាក្នុងការចូលរៀន។ ភី អ ឌីបានផ្តល់សម្ភារៈសិក្សាពេញមួយឆ្នាំ ឯកសណ្ឋាន និងតម្រូវការចាំបាច់ផ្សេងទៀតសម្រាប់បន្តការសិក្សានៅសាលា។ ភី អ ឌី អនុវត្តកម្មវិធីអាហារូបករណ៍ក៏ជាកម្មវិធីតភ្ជាប់ជាមួយកម្មវិធីទប់ស្កាត់អត្រាបោះបង់ការសិក្សារបស់ក្រសួងអប់រំផងដែរ។

### ២.៤.១ ការគាំទ្រសម្ភារៈសិក្សាប្រចាំឆ្នាំ

ភី អី ឌី បានផ្តល់ជំនួយសម្ភារៈសិក្សាមួយដងដល់សិស្សអាហារូបករណ៍ចំនួន ៤១នាក់ រួមមានសិស្សអាហារូបករណ៍នៅភូមិភ្នំរ៉ៃ និងសុខសាន្ត (សិស្ស៣១នាក់នៅសំឡូត និងសិស្ស១០នាក់នៅប៉ៃលិន) ដើម្បីធានាថាសិស្សស្រីទាំងអស់មានសម្ភារៈគ្រប់គ្រាន់សម្រាប់ប្រើប្រាស់សម្រាប់ឆ្នាំសិក្សាថ្មីរបស់ពួកគេ។ ជំនួយសម្ភារៈក៏ត្រូវបានបែងចែកខុសៗគ្នាទៅតាមកម្រិតសិស្សស្រីចាប់ពីបឋមសិក្សាដល់វិទ្យាល័យ។





## ២.៤.២ ការតាមដានការសិក្សានៅតាមសាលារៀន

ភី អ ឌី បានធ្វើការតាមដានជាប្រចាំជាមួយសិស្សអាហារូបករណ៍នៅក្នុងសាលា ដើម្បីបន្តការលើកទឹកចិត្ត និងពង្រឹងពួកគេក្នុងការសិក្សា ដើម្បីឱ្យសិស្សអាហារូបករណ៍ទាំងអស់អាចមានឱកាសចែករំលែកនូវអ្វីដែលដំណើរការល្អ ឬអ្វីដែលមិនល្អ។





## ២.៤.៣ ការប្រជុំប្រចាំត្រីជាមួយសិស្សស្រី និងអាណាព្យាបាល

ដើម្បីធានានូវភាពជោគជ័យនៃការគាំទ្រកម្មវិធីអាហារូបករណ៍សម្រាប់សិស្សស្រី ភី អ ឌី បានធ្វើការយ៉ាងជិតស្និទ្ធជាមួយឪពុកម្តាយរបស់អាហារូបករណ៍ទាំងអស់ដើម្បីរក្សាការយល់ដឹងយ៉ាងច្បាស់អំពីរបៀបជួយគ្នាទៅវិញទៅមក ជាពិសេសដើម្បីរក្សាកូនរបស់ពួកគេឱ្យចូលរៀន និងមានការអប់រំល្អសម្រាប់អនាគត់។ ក្នុងកិច្ចប្រជុំនីមួយៗ អ្នកសម្របសម្រួលផ្នែកអប់រំរបស់ ភី អ ឌី បានដឹកនាំមាតាបិតាឲ្យគិតដល់ចំណុចបី (១) សកម្មភាពដែលជះឥទ្ធិពលល្អសម្រាប់កូន និងការសិក្សា (២) សកម្មភាពដែលជះឥទ្ធិពលមិនល្អសម្រាប់កូន និងការសិក្សា (៣) អ្វីដែលត្រូវធ្វើដើម្បី កែលម្អវាឱ្យកាន់តែប្រសើរឡើងនៅពេលក្រោយសម្រាប់កូនៗ និងការសិក្សារបស់ពួកគេ។ ជាងនេះទៅទៀត នៅខែវិច្ឆិកា ឆ្នាំ ២០២៣ ភី អ ឌី បានបើកកិច្ចប្រជុំជាមួយឪពុកម្តាយ ២១នាក់ និងសិស្សស្រី ១៩នាក់នៅភ្នំរ៉ៃ និងសុខសាន្ត ដើម្បីពិភាក្សាអំពីតួនាទី និងការទទួលខុសត្រូវរបស់ ភី អ ឌី សម្រាប់ការគាំទ្រសិស្សស្រី លទ្ធផលសិក្សា និងផែនការបន្ទាប់នៅឆ្នាំ ២០២៤ ។





## ២.៤.៤ ការចុះសួរសុខទុក្ខដល់ផ្ទះអំឡុងពេលវិស្សមកាល

នៅឆ្នាំ ២០២៣ គឺជាកាលវិភាគដ៏មមាញឹករបស់ប្រទេសកម្ពុជាក្នុងការធ្វើជានម្ចាស់ផ្ទះស្វាគមន៍ការប្រកួតកីឡាជាតិ និងកីឡាស៊ីហ្គេមឆ្នាំ២០២៣ ដូច្នេះសាលារៀនទាំងអស់ត្រូវបិទជិត ២ ខែ ដោយបូករួមទាំងបុណ្យចូលឆ្នាំខ្មែរផងដែរ។ ភី អ ឌី ព្រួយបារម្ភអំពីសុខទុក្ខរបស់សិស្សអាហារូបករណ៍ក្នុងអំឡុងពេលវិស្សមកាលដ៏វែងនេះ អ្នកសម្របសម្រួលផ្នែកអប់រំបានចុះទៅដល់ផ្ទះដោយផ្ទាល់ទៅកាន់សិស្សអាហារូបករណ៍ទាំងអស់ និងជួបឪពុកម្តាយរបស់ពួកគេ ដើម្បីតាមដានស្ថានភាពរស់នៅរបស់ពួកគេ រៀបចំផែនការបន្ទាប់ពីវិស្សមកាល ជួបគណៈកម្មាធិកាសាលា និងដើម្បីបង្កើតទំនាក់ទំនងបន្ថែមទៀតជាមួយពួកគេ។





## ២.៤.៥ ការផ្តល់អង្ករប្រចាំខែ ការរៀនបំប៉នបន្ថែម និងគាំទ្រអាហារប្រចាំថ្ងៃ

នៅឆ្នាំ ២០២៣ ភី អ ឌីបានរក្សាការឧបត្ថម្ភអង្ករប្រចាំខែដល់សិស្សអាហារូបករណ៍ចំនួន ៤១ នាក់ (នៅសំឡូត៣១ នាក់ និងប៉ៃលិន១០នាក់) ដើម្បីឱ្យពួកគេមានអង្ករហូបគ្រប់គ្រាន់។ ការឧបត្ថម្ភអង្ករប្រចាំខែ គឺជាផ្នែកមួយទៀតនៃកម្មវិធីអាហារូបករណ៍ដើម្បីលើកទឹកចិត្តគ្រួសារបញ្ជូនកូនទៅសាលារៀន ជាជាងនាំពួកគេទៅធ្វើការដើម្បីចិញ្ចឹម ជីវិត។ ក្នុងមួយគ្រួសារទទួលបានអង្ករ ៣០គីឡូក្រាម ឬ ៥០គីឡូក្រាមអាស្រ័យលើទំហំគ្រួសារ (៣០គីឡូក្រាមសម្រាប់គ្រួសារទំហំតូច)។ ក្រៅពីនេះ ភី អ ឌីបានគាំទ្របន្ថែមសម្រាប់សិស្សដែលស្នាក់នៅអន្តេវាសិកដ្ឋានចំនួន១០មុីនរៀនក្នុងមួខែ និងមានតម្រូវការរៀនបំប៉នបន្ថែមចំនួន៣មុខវិជ្ជា ដូចជា គណិតវិទ្យា រូបវិទ្យា និងភាសាខ្មែរ។





លើសពីនេះទៅទៀត ភី អ ឌី បានរកឃើញការគាំទ្រមួយផ្សេងទៀតដើម្បីជួយសិស្សអាហារូបករណ៍ទាំងអស់ទៅសរៀនរហូតដល់ពួកគេអាចបញ្ចប់ការសិក្សា។ ការរៀនបំប៉នបន្ថែម និងអាហារប្រចាំថ្ងៃសម្រាប់សិស្សអាហារូបករណ៍ដែលរស់នៅឆ្ងាយពីសាលារៀន ហើយពួកគេត្រូវរស់នៅក្នុងអន្តេវាសិកដ្ឋានក្នុងសាលារៀន។ ការគាំទ្រនេះនឹងពង្រឹងពួកគេឱ្យមានពេលវេលាគ្រប់គ្រាន់នៅក្នុងសាលា ដើម្បីផ្តោតអារម្មណ៍ទាំងស្រុងលើការសិក្សា។





## ៣. គម្រោងអភិរក្សវប្បធម៌ និងភាសារបស់ជនជាតិដើមភាគតិច (ព័រ)

នៅខែកុម្ភៈ ឆ្នាំ ២០២៣ ភី អ ឌី បានធ្វើការជាមួយមេភូមិភ្នំរ៉ៃ នាយកសាលា អ្នកដឹកនាំក្លឹបជនជាតិព័រ និងព្រឹទ្ធាចារ្យជនជាតិព័រ ដើម្បីពិភាក្សាលើការអភិរក្សវប្បធម៌ និងភាសារបស់ជនជាតិព័រ ។ អង្គប្រជុំបានសម្រេចបង្កើតក្លឹបភាសាព័រ និងគណៈកម្មាធិការអភិរក្សវប្បធម៌ព័រ។ កម្មវិធីទាំងនេះមានគោលបំណងថែរក្សា និងផ្សព្វផ្សាយវប្បធម៌ និងអត្តសញ្ញាណជនជាតិព័រដោយបានសហការជាមួយមន្ទីរ និងក្រសួងអភិវឌ្ឍជនបទ។

### ៣.១ គម្រោងក្លឹបភាសាជនជាតិដើមភាគតិច (ព័រ)

ក្លឹបភាសាព័រត្រូវបានបង្កើតឡើង និងបើកដំណើរការនៅថ្ងៃទី ១ ខែមីនា ឆ្នាំ ២០២៣។ កម្មវិធីនេះគាំទ្រក្លឹបភាសាព័រចំនួន ២សម្រាប់សិស្ស ៤០នាក់ (ស្រី ២៣នាក់)។

- បានប្រគល់វគ្គបណ្ដុះបណ្ដាលចំនួន ៤ ដល់គ្រូភាសាព័រស្តីពីការផលិតសម្ភារៈបង្រៀនជាភាសាព័រសម្រាប់ថ្នាក់រៀន និងវិធីសាស្ត្របង្រៀន។
- ផ្តល់សម្ភារៈបង្រៀនសម្រាប់គ្រូបង្រៀនដូចជា ក្រដាសកាតុងធ្វើកេស ផ្ទាំងក្រដាស សញ្ញាសម្គាល់អចិន្ត្រៃយ៍ សញ្ញាសម្គាល់ក្តារខៀន ក្រដាសជូតមាត់ ក្រដាស A4 និងក្រដាសពណ៌ A4 (2ដងក្នុងមួយឆ្នាំ)។

ក្លឹបភាសាព័របានបែងចែកជា២ក្រុមផ្សេងគ្នា ក្លឹបមួយជួបពេលព្រឹក និងក្លឹបមួយជួបពេលរសៀល ។ សិស្សរៀនមួយម៉ោងក្នុងមួយសប្តាហ៍ ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ រៀងរាល់សប្តាហ៍សម្រាប់រយៈពេល ១០ ខែ។

### ៣.២ គម្រោងអភិរក្សវប្បធម៌ជនជាតិដើមភាគតិច (ព័រ)

នៅខែសីហា ឆ្នាំ ២០២៣ ភី អ ឌី បានសហការជាមួយមេភូមិភ្នំរ៉ៃ និងក្រុមប្រឹក្សាឃុំដឹកនាំកិច្ចប្រជុំជាមួយអ្នកដឹកនាំជនជាតិព័រ និងព្រឹទ្ធាចារ្យជនជាតិព័រសម្រាប់បង្កើតគណៈកម្មាធិការអភិរក្សវប្បធម៌ព័រ។ អង្គប្រជុំមាន ២៥ នាក់ (១៥ នាក់) ចូលរួមប្រជុំ ហើយសម្រេចបង្កើតគណៈកម្មការចំនួន ៥ ដូចខាងក្រោម៖

- គណៈកម្មាធិការគ្រប់គ្រងវប្បធម៌ព័រ (៧នាក់)
- គណៈកម្មាធិការសារមន្ទីរ៉ (៧នាក់)
- គណៈកម្មាធិការរាំ និងតន្ត្រី (៥នាក់)
- គណៈកម្មាធិការអាហារវប្បធម៌ព័រ (៧នាក់)
- ក្រុមយុវជនព័រ (៥នាក់)

នៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០២៣ ភី អ ឌី បានបើកកិច្ចប្រជុំជាមួយមេភូមិភ្នំរ៉ៃ សមាជិកក្រុមប្រឹក្សាឃុំតាតោក និងគណៈកម្មាធិការជនជាតិព័រទាំងអស់ ដើម្បីពិភាក្សាអំពីវប្បធម៌ជនជាតិព័រនាពេលអនាគត។ ក្នុងការជួបសំណេះសំណាលនោះ អ្នកដឹកនាំជនជាតិព័របានផ្តល់ដីជាកម្មសិទ្ធិរបស់គាត់ទំហំ ១៤ម៉ែត្រ x ២៧ម៉ែត្រ ឲ្យក្រុមជនជាតិព័រជំនាន់ក្រោយប្រើប្រាស់ក្នុងការអភិរក្សវប្បធម៌ជនជាតិព័រ។ នៅពេលនេះ កន្លែងនោះមានផ្ទះរបស់មេកន្រទាញ សារមន្ទីរ និងកន្លែងសម្រាប់ធ្វើពិធី។ ភី អ ឌី បានគ្រោងនឹងសាងសង់មជ្ឈមណ្ឌលវប្បធម៌ប្រពៃណី ម្ហូបអាហារ និងជួសជុលសារមន្ទីរសម្រាប់ផ្សព្វផ្សាយវប្បធម៌របស់ជនជាតិព័រ។ អ្នកចូលរួមមានចំនួន ២៣ នាក់ (ស្រី ១៦ នាក់) ។

នៅថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០២៣ ភី អ ឌី បានសហការជាមួយមន្ទីរអភិវឌ្ឍន៍ជនបទខេត្តបាត់ដំបង និងក្រសួងអភិវឌ្ឍន៍ជនបទ បើកកិច្ចប្រជុំផ្តោតលើការពង្រឹងសមត្ថភាពដល់គណៈកម្មាធិការជនជាតិព័រនៅវត្តភ្នំរ៉ៃមានអ្នកចូលរួម ៧៣នាក់ (ស្រី ៣៨នាក់)។ នៅថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ ២០២៣ ភី អ ឌី បានសហការជាមួយមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និងក្រសួងអភិវឌ្ឍន៍ជនបទប្រារព្ធទិវាអន្តរជាតិជនជាតិដើមភាគតិច (ជនជាតិព័រ) នៅវត្តភ្នំរ៉ៃ ដែលមានប្រជាពលរដ្ឋចូលរួមសរុបចំនួន ១៥៣នាក់ (ស្រី ៧២ នាក់) រួមមានអភិបាលរងខេត្ត អភិបាលស្រុក និងមន្ទីរចំនួន ៧ ក្នុងខេត្តបាត់ដំបង ដូចជា អង្គការការិយាល័យអប់រំ ការិយាល័យបរិស្ថាន សុខាភិបាល កសិកម្ម វប្បធម៌ ធនធានទឹក រ៉ែ និងថាមពល។






នៅខែតុលា ឆ្នាំ ២០២៣ កិច្ចប្រជុំប្រចាំត្រីមាសជនជាតិដើមភាគតិចដែលបានចូលរួមនៅរាជធានីភ្នំពេញដោយកិច្ចប្រជុំផ្តោតលើ៖

- របាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសពី NGOs/ក្រុមហ៊ុនធ្វើការជាមួយជនជាតិដើមភាគតិច។
- កិច្ចសហប្រតិបត្តិការរវាងអង្គការក្រៅរដ្ឋាភិបាល ក្រុមហ៊ុន និងក្រសួងអភិវឌ្ឍន៍ជនបទ
- ផែនការបន្ទាប់ក្នុងត្រីមាសទី ៤ ។

## ៤. កិច្ចសហប្រតិបត្តការនានា និងដៃគូ

### ៤.១. បណ្តាញអប់រំប្រចាំខេត្តបាត់ដំបង

ក្រុមគាំទ្រវិស័យអប់រំខេត្តបាត់ដំបង (BEST) គឺជាបណ្តាញអប់រំឈានមុខក្នុងខេត្តបាត់ដំបង។ BEST មានគោលបំណងគាំទ្រ និងកែលម្អគុណភាពអប់រំក្នុងចំណោមបណ្តាញដោយបង្កើតឯកសារគោលការណ៍នែនាំសម្រាប់បណ្តាញ ធ្វើការប្រជុំទៀងទាត់ ធ្វើការស្រាវជ្រាវលើប្រធានបទអប់រំដែលពាក់ព័ន្ធ និងធ្វើការទំនាក់ទំនងយ៉ាងជិតស្និទ្ធ ដើម្បីបញ្ចេញសំឡេងលើបញ្ហាប្រឈម និងផ្នែកនានាដែលមានតម្រូវការសម្រាប់អន្តរាគមន៍។ នៅក្នុងឆ្នាំ ២០២៣ នេះ BEST និងសមាជិកបានធ្វើការស្រាវជ្រាវតូចៗស្តីពី "សុវត្ថិភាពចំណីអាហារ និងការយល់ដឹងអំពីសុវត្ថិភាពចំណីអាហារនៅក្នុងសាលា"។




## ៤.២. សមាគមន៍ពេទ្យធ្មេញស្ម័គ្រចិត្ត ( DENTAID )

ភី អ ឌី បានសហការជាមួយអជ្ញាធរខេត្ត សហភាពសហព័ន្ធយុវជនកម្ពុជាខេត្ត (ស.ស.យ.ក) រដ្ឋបាលស្រុកសំឡូត និងសមាជិកឃុំគោលដៅដើម្បីគាំទ្រដល់ដំណើរការចុះអនុវត្តកម្មវិធីថែទាំសុខភាពមាត់ធ្មេញរបស់ក្រុមគ្រូពេទ្យស្ម័គ្រចិត្តមកពីចក្រភពអង់គ្លេស(Dentaid) ។ Dentaid គឺជាបណ្តាញមួយក្នុងចំណោមបណ្តាញដែលធ្វើការដើម្បីគាំទ្រសុខភាពមាតធ្មេញសម្រាប់កុមារនៅក្នុងសាលារដ្ឋ។ ភី អ ឌី បានធ្វើការជាមួយក្រុម Dentaid ដើម្បីធ្វើការអប់រំពីសុខភាពមាត់ធ្មេញ និងពិនិត្យធ្មេញ។ ចាប់ពីថ្ងៃទី ១៣ ដល់ថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ ២០២៣ ក្រុមការងារ ភី អ ឌី និងក្រុមគ្រូពេទ្យស្ម័គ្រចិត្ត (Dentaid) ចំនួន ១៣នាក់ (ស្រី១២នាក) ដឹកនាំដោយលោកវេជ្ជបណ្ឌិត សាយម៉ុន គ្រូវ (Doctor Simon Crewe) និងសម្របសម្រួលដោយអ្នកសម្របសម្រួលផ្នែកអប់រំរបស់ភី អ ឌី បានធ្វើការអប់រំសុខភាពមាត់ធ្មេញដល់កុមារជាង ៣០០នាក់នៅក្នុងសាលាបឋមសិក្សាគោលដៅចំនួន ៣សាលា (សាលាបឋមសិក្សាដូនត្រឹតវាលផ្កា និងសាលាបឋមសិក្សាទ្រុងខ្លា) នៅស្រុកសំឡូត។






**************************************************************

ថ្ងៃចន្ទ ៣កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧
បាត់ដំបង ថ្ងៃច័ន្ទ ទី១២ ខែកុម្ភៈ ឆ្នាំ២០២៤

**រៀបចំ និងធ្វើរបាយការណ៍ដោយ**

**អ្នកសម្របសម្រួលផ្នែកអប់រំ**

---

**លោក បឿត ចាន់តុលា**

ថ្ងៃចន្ទ ៣កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧
បាត់ដំបង ច័ន្ទ ទី១២ ខែកុម្ភៈ ឆ្នាំ២០២៤

**បានឃើញ និងពិនិត្យដោយ**

**នាយិកាប្រចាំប្រទេស**

---

# អង្គការ
# ដៃគូដើម្បីការអភិវឌ្ឍជនបទ( ភី អ ឌី )

♦♦♦♦♦♦♦♦♦♦♦♦♦♦♦♦♦♦

# របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៣

# របាយការណ៍ចំណូល ចំណាយ
# ប្រចាំឆ្នាំ២០២៣

| បរិយាយ | ចំណូល (ពាន់រៀល) | ចំណាយ (ពាន់រៀល) |
|---|---|---|
| **ចំណាយផ្នែករដ្ឋបាល** | | |
| ចំណាយបៀវត្សន៍បុគ្គលិករដ្ឋបាល | 30,637.50 | 35,621.20 |
| ចំណាយថ្លៃជួល និងទឹកភ្លើង ការិយាល័យ | 6,127.50 | 5,930.03 |
| ចំណាយថ្លៃទំនាក់ទំនង ទូរស័ព្ទ និងវេបសាយ | 2,042.50 | 3,516.74 |
| ចំណាយថ្លៃសម្ភារការិយាល័យ | 2,451.00 | 2,285.68 |
| ចំណាយជួសជុល និងតំហែទាំ | 817.00 | 561.69 |
| ចំណាយថ្លៃសាំងនិងធ្វើដំណើរ | 408.50 | 914.30 |
| ចំណាយការប្រជុំនិងវគ្គបណ្ដុះបណ្ដាលបុគ្គលិក | 817.00 | 2,265.17 |
| ចំណាយផ្សេងៗ | 555.56 | 1,256.51 |
| **សរុបចំណាយផ្នែករដ្ឋបាល** | **43,856.56** | **52,351.32** |
| **ចំណាយផ្នែកសកម្មភាពគម្រោង** | | |
| ចំណាយលើគម្រោងស្រាវជ្រាវដំណាំដំឡូងមី | - | 121,346.48 |
| ចំណាយលើគម្រោងស្រាវជ្រាវកសិកម្មជំនាន់ថ្មី | 1,386,194.34 | 785,453.87 |
| ចំណាយលើកម្មវិធីអប់រំនិងយេនឌ័រ | 2,042.50 | 194,595.51 |
| ចំណាយលើកម្មវិធីលើកកម្ពស់ជីវភាពសហគមន៍ និងជនជាតិដើមភាគតិច | 1,031,441.99 | 881,427.39 |
| ចំណាយលើគម្រោងគន្ធានិងគោរីករាយ | - | 200.17 |
| **សរុបចំណាយផ្នែកសកម្មភាពគម្រោង** | **2,419,678.83** | **1,983,023.42** |
| | | |
| សរុបរួម | **2,463,535.39** | **2,035,374.74** |

ថ្ងៃសុក្រ ៧កើត ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
ធ្វើនៅបាត់ដំបង, ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៤
នាយិកាអង្គការ

នួន សុគន្ធា

# BUDGET VS EXPENDITURE 2023

| BUDGET/ EXPENDITURE | BUDGET (USD) | SPENT (USD) |
|---|---|---|
| **ADMINISTRATION COSTS** | | |
| Admin Staff salaries | 7,500.00 | 8,720.00 |
| Rent/Utilities (Water supplies & electricity) | 1,500.00 | 1,451.66 |
| Communication (phone, Internet, and website) | 500.00 | 860.89 |
| Office supplies & Overhead | 600.00 | 559.53 |
| Equipment Repair & Maintenance | 200.00 | 137.50 |
| Travel & Fuel | 100.00 | 223.82 |
| Team meeting/workshop | 200.00 | 554.51 |
| Contingency | 136.00 | 307.59 |
| **TOTAL ADMINISTRATION COSTS** | **10,736** | **12,815.50** |
| **PROGRAM COSTS** | | |
| Agriculture (Cassava Research Project) | 0 | 29,705.38 |
| Agriculture (Next Generation Agricultural Extension) | 339,337.66 | 192,277.57 |
| Education & Women Empowerment | 500.00 | 47,636.60 |
| Livelihood & Indigenous | 252,494.98 | 215,771.70 |
| The Happy Cow Project | 0 | 49.00 |
| **TOTAL PROGRAM IMPLEMENT COSTS** | **592,332.64** | **485,440.25** |
| | | |
| **GRAND TOTAL (U.S. DOLLARS)** | **603,068.64** | **498,255.75** |

**Date: 16/February/2024**
**Approved by: Country Director**

**Nuon Sokunthea**

❖ **បញ្ជីឧបសម្ព័ន្ធបន្ថែម**

បញ្ជីអក្សរកាត់

កិច្ចសហប្រត្តិបត្តការភាពជាដៃគូក្នុងស្រុក

ប្រភពម្ចាស់ជំនួយ

តារាងឈ្មោះសាលាគោលដៅរបស់ ភី អ ឌី ឆ្នាំ២០២៣

❖ **បញ្ជីអក្សរកាត់**

- PRD (Partners for Rural Development)
- DoEYS (District of Education Youth and Sport)
- PoE (Provincial of Education)
- ETFO (Elementary Teachers΄ Federation of Ontario)
- BEST (Battambang Education Support Team)
- GFP (Gender Focus Partners)
- UYFC (Union of Youth Federations of Cambodia)
- CCWC (Commune Committee for Women and Children)

❖ **កិច្ចសហប្រត្តិបត្តការភាពជាដៃគូក្នុងស្រុក**

អង្គការ ភី អ ឌី បានរក្សាកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូពាក់ព័ន្ធពីកម្រិតសហគមន៍រហូតដល់ថ្នាក់ខេត្ត។

- ចុះកិច្ចព្រមព្រៀងជាមួយភាពជាដៃគូនៅថ្នាក់ស្រុក និងខេត្ត ទាំងនៅខេត្តបាត់ដំបង និងប៉ៃលិន។
- បានចុះឈ្មោះជាមួយនាយកដ្ឋានពន្ធដារ។
- បានចុះឈ្មោះជាមួយនាយកដ្ឋានកិច្ចការការងារ
- សមាជិកនៃ BEST (បណ្តាញអប់រំ) ពីឆ្នាំ 2017 ហើយចូលរួមជាញឹកញាប់នៅក្នុងការប្រជុំ ឬសកម្មភាពផ្សេងៗ។
- សមាជិកបណ្តាញ NGOs ក្នុងខេត្តបាត់ដំបង
- សមាជិកបណ្តាញជាមួយរដ្ឋាភិបាលខេត្តបាត់ដំបង
- រក្សាកិច្ចសហប្រតិបត្តិការល្អជាមួយអាជ្ញាធរ មេភូមិ និងមេឃុំ មន្ទីរពាក់ព័ន្ធខេត្ត និងស្រុកនៅតាមតំបន់គោលដៅ។
- បន្តធ្វើការ និងកសាងទំនាក់ទំនងល្អជាមួយដៃគូដែលមានស្រាប់ អ្នកពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធថ្មីផ្សេងទៀតនៅថ្នាក់ស្រុក និងខេត្ត។
- បញ្ជូនរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំទៅកាន់ដៃគូ និងអ្នកពាក់ព័ន្ធទាំងអស់។

- ចូលរួមកិច្ចប្រជុំ និងសិក្ខាសាលានានាដែលត្រូវបានអញ្ជើញដោយរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលសហប្រតិបត្តិការ។

❖ **ប្រភពម្ចាស់ជំនួយ**

អង្គការភី អ ឌី បានទទួលមូលនិធិជាជំនួយផ្នែកហិរញ្ញវត្ថុដោយសប្បុរស និងពីម្ចាស់ជំនួយខាងក្រោមៈ

- សហព័ន្ធគ្រូបង្រៀនមធ្យមសិក្សានៅអង់តារីយ៉ូ ប្រទេសកាណាដា (ETFO)៖ គាំទ្រកម្មវិធីអប់រំ- ការអប់រំសម្រាប់ទាំងអស់គ្នានៅជនបទកម្ពុជា
- មជ្ឈមណ្ឌលអូស្ត្រាលីដើម្បីការស្រាវជ្រាវកសិកម្មអន្តរជាតិ (Australian Center for International Agricultural Research – ACIAR)
- DENTAID-The Dental Charity នៅចក្រភពអង់គ្លេស៖ ផ្តោតលើកម្មវិធីសុខភាពមាត់ធ្មេញនៅតាមសាលាបឋមសិក្សា។
- ម្ចាស់ជំនួយមកពីគ្រប់ប្រភព

❖ **តារាងឈ្មោះសាលាគោលដៅរបស់ ភី អ ឌី ឆ្នាំ២០២៣**

| ល.រ | ឈ្មោះសាលាគោលដៅស្រុកសំឡូត | ទីតាំងសាលាគោលដៅ |
|---|---|---|
| ១ | សាលាបឋមសិក្សាមានជ័យ | ភូមិកំចាត់ ឃុំមានជ័យ ស្រុកសំឡូត ខេត្តបាត់ដំបង |
| | សាលាឧបសម្ព័ន្ធមានជ័យ | |
| ២ | សាលាបឋមសិក្សាដូនត្រីត | ភូមិដូនត្រីត ឃុំតាសាញ ស្រុកសំឡូត ខេត្តបាត់ដំបង |
| | សាលាឧបសម្ព័ន្ធដូនត្រីត | |
| ៣ | សាលាបឋមសិក្សាព្រៃរំចេក | ភូមិព្រៃរំចេក ឃុំតាសាញ ស្រុកសំឡូត ខេត្តបាត់ដំបង |
| ៤ | សាលាបឋមសិក្សាទ្រុងខ្លា | ភូមិចំលងរមាំងលើ ឃុំអូរសំរិល ស្រុកសំឡូត ខេត្តបាត់ដំបង |
| | សាលាឧបសម្ព័ន្ធអូរអន្សង | |
| ៥ | សាលាបឋមសិក្សាវាលធ្នា | |
| | សាលាឧបសម្ព័ន្ធបុស្សរកា | |
| ៦ | សាលាបឋមសិក្សាភ្នំរ៉ៃ | ភូមិភ្នំរ៉ៃ ឃុំតាតោក ស្រុកសំឡូត ខេត្តបាត់ដំបង |
| ៧ | សាលាបឋមសិក្សាសុខសាន្ត | |
| | ឈ្មោះសាលាគោលដៅស្រុកសំឡូត | ទីតាំងសាលាគោលដៅ |
| ៨ | សាលាបឋមសិក្សាពេជ្រគិរី | ភូមិពេជ្រគិរី សង្កាត់ប៉ៃលិន ក្រុង/ខេត្តប៉ៃលិន |
| ៩ | សាលាបឋមសិក្សាទឹកផុស | ភូមិទឹកផុស សង្កាត់ប៉ៃលិន ក្រុង/ខេត្តប៉ៃលិន |
| ១០ | សាលាបឋមសិក្សាអណ្តូងថ្ម | ភូមិអូរអណ្តូង ឃុំអូរអណ្តូង ស្រុកសាលាក្រៅ ខេត្តប៉ៃលិន |